សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# លទ្ធផលការងាររបស់បេឡាជាតិរបបសន្តិសុខសង្គម រយៈពេល១០ឆ្នាំ ២០០៨-២០១៧

ស្រាវជ្រាវពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ក.ណៃ សុខម៉េង**
**ក.សូត សួន**

សាស្រ្តាចារ្យណែនាំ
លោក **ម៉ៅ បុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**
ជំនាន់ទី១៩

ឆ្នាំចូលរៀន ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីរនាក់ **ណៃ សុខម៉េង** និង**សួត សួន** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិ-សាស្ត្រឆ្នាំទី៤ ជំនាន់ទី១៨ (ថ្នាក់L4B1) ឆ្នាំសិក្សា២០១៨ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមលំអោនកាយគោរព** និង**ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ លោកឪពុក** និង**អ្នកម្ដាយ** ជាទីគោរពយ៉ាងខ្ពង់ខ្ពស់ដែលបានផ្ដល់កំណើតឱ្យកូន ចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចក្រូចឆ្មារហូតដល់ធំពេញវ័យ។ លោកទាំងពីរបាន រៀបចំទំនុកបម្រុងឱ្យកូនរៀនបានខ្ពង់ខ្ពស់ មើលថែថ្នាក់ថ្នមកូនមិនខ្លាចនឿយហត់ ព្រមទាំងទូន្មានប្រៀនប្រដៅអប់រំឱ្យកូនក្លាយជា កូនល្អ ពលរដ្ឋល្អ បានជាប្រយោជន៍ដល់សង្គមជាតិ និងជាទីស្រឡាញ់នៃអ្នកដទៃ។ សេចក្ដីស្រឡាញ់ ក្ដីបារម្ភ និងការលើកទឹកចិត្តរបស់លោកអ្នកមានគុណទាំងពីរ បានធ្វើឱ្យកូន ទទួលបានជោគជ័យក្នុងការបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រចប់ជាស្ថាពរ។

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យ** និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា ព្រមទាំងបណ្ណារក្ស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹងនាំគ្រប់គ្រង និងបង្ហាត់បង្រៀនយើងខ្ញុំឱ្យទទួលបានចំណេះវិជ្ជាយ៉ាងច្រើន។

លោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណា** ដែលបានជួយធ្វើការណែនាំ និងជួយធ្វើការពន្យល់ព្រមទាំងជួយផ្ដល់ទាំងវិធីសាស្ត្រ និងការកែតម្រូវសារណានេះ យ៉ាងយកចិត្តទុកដាក់បំផុត។

ខ្លូស្ពន់ស័រ (CLEW Sponsors) ដែលបានជួយឧបត្ថម្ភយើងខ្ញុំទាំងពីរនាក់រហូតដល់បញ្ចប់បរិញ្ញា-បត្រ។

កញ្ញា **សន សុខឡែន** ជាសិស្សច្បងដែលបានណែនាំ និងផ្ដល់ជាយោបលក្នុងសារណាមួយនេះ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមសម្ដែងនូវសេចក្ដីគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជាពិសេសសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងបួងសួងឱ្យវត្ថុស័ក្តិសិទ្ធិក្នុងលោកតាមថែរក្សា លោកទាំងអស់ឱ្យជួបតែសេចក្ដីសុខ និងជ័យជំនះគ្រប់ភារកិច្ច។

# អារម្ភកថា

ប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ដែលមានដៃគូវិនិយោគច្រើន ហើយអ្នកវិនិយោគទុនបានសាងសង់រោងចក្រ សហគ្រាស គ្រឹះស្ថាន ជាច្រើនក្នុងប្រទេសកម្ពុជា ជាពិសេសនៅទីក្រុងភ្នំពេញ ដែលជាហេតុធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាមានឱកាសមានការងារច្រើន។ ក្នុងនោះ នៅក្នុងនាមជានិយោជក (ថៅកែ) គាត់បានបង់ភាគទានដល់បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីឱ្យកម្មករនិយោជិតមានភាពងាយស្រួលនៅពេលដែលពួកគាត់មានជំងឺ ជួបគ្រោះថ្នាក់ការងារ បញ្ហាសុខភាព និងនៅពេលគាត់ចាស់ជរា។ នៅពេលដែលកម្មករនិយោជិតជួបប្រទះបញ្ហាណាមួយក្នុងចំណោម បញ្ហាខាងលើនេះ មានតែបេឡាជាតិរបបសន្តិសុខសង្គមទេដែលអាចជួយផ្តល់ជាជំនួយដ៏ល្អប្រសើរដល់ពួកគាត់។ លើសពីនេះទៀត បេឡាជាតិរបបសន្តិសុខសង្គមមានសមិទ្ធផលតាំងពីពេលដែលចាប់ផ្តើមបង្កើតរហូតដល់ពេលបច្ចុប្បន្ន ដែលនិស្សិតមួយចំនួនមិនទាន់បានដឹងនៅឡើយ។

អាស្រ័យហេតុនេះ បានជំរុញឱ្យយើងខ្ញុំទាំងពីរ សិក្សាស្រាវជ្រាវប្រធានបទមួយស្តីពី **លទ្ធផលការងាររបស់បេឡាជាតិរបបសន្តិសុខសង្គមរយៈពេល១០ឆ្នាំ(២០០៨-២០១៧)**។ យើងខ្ញុំយល់ថា បេឡាជាតិរបបសន្តិសុខសង្គមបានសម្រេចលទ្ធផលជាច្រើន ដែលចូលរួមជួយ សម្រួលដល់ការរស់នៅ ជីវភាពរបស់កម្មករនិយោជិតពេលដែលគាត់ជួបហេតុការជាបន្ទាន់ណាមួយជាពិសេសផ្នែកហានិភ័យការងារ និងផ្នែកសុខភាព ។

យើងខ្ញុំទាំងពីរសង្ឃឹមថា ប្រធានបទមួយនេះនឹងផ្តល់អត្ថប្រយោជន៍ ក្នុងការសិក្សាស្រាវជ្រាវរបស់ប្អូនៗជំនាន់ក្រោយ។

ការស្រាវជ្រាវមួយនេះ គឺជាស្នាដៃដំបូងរបស់យើងទាំងពីរនាក់ ហេតុនេះយើងខ្ញុំជឿជាក់ថា ពិតជាមានភាពខ្វះខាត និងមានកំហុសខ្លះជាមិនខាន។ ដូចនេះ យើងខ្ញុំទាំងពីរនាក់រង់ចាំទទួលយកការរិះគន់ដើម្បីកែលំអ ក្នុងន័យស្ថាបនាចំពោះស្នាដៃមួយនេះដោយសេចក្តីរីករាយ។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីររូប សូមគោរពជូនពរដល់លោក លោកស្រីជាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងមិត្តៗ និស្សិតទាំងអស់ឱ្យ ជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ...... ១

**ជំពូកទី១**

**សញ្ញាណទូទៅ និងលទ្ធផលការងារ**

**ផ្នែកទី១៖ និយមន័យបេឡាជាតិរបបសន្តិសុខសង្គម** ...... ២

**១.១ ប្រវត្តិបេឡាជាតិរបបសន្តិសុខសង្គម** ...... ៣

**១.២. ភារកិច្ច និងរចនាសម្ព័ន្ធ** ...... ៤

១.២.១ ភារកិច្ច ...... ៤

១.២.២ រចនាសម្ព័ន្ធ ...... ៥

**ផ្នែកទី២៖ លទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០០៨-២០១៧** ...... ៦

**២.១. ការអនុវត្តរបបសន្តិសុខសង្គមលើហានិភ័យការងារ** ...... ៦

២.១.១ បញ្ជិកា និងភាគទាន ...... ៦

២.១.២ អធិការកិច្ច និងនីតិកម្ម ...... ៩

២.១.៣ គាវកាលិក ...... ១០

**២.២. ដំណើរការរបបសន្តិសុខសង្គមសម្រាប់ថែទាំសុខភាព** ...... ១៤

២.២.១ បញ្ជិកា និងភាគទាន ...... ១៤

២.២.២ អធិការកិច្ច និងនីតិកម្ម ...... ១៥

២.២.៣ សេវាគាវកាលិក ...... ១៦

**២.៣ ប្រាក់សោធន** ...... ១៧

**ផ្នែកទី៣៖ ការអនុវត្តជាក់ស្តែង** ...... ១៨

**៣.១ គោលនយោបាយ និងលិខិតគតិយុត្ត** ...... ១៨

**៣.២ ការគ្រប់គ្រង និងការបណ្តុះបណ្តាលធនធានមនុស្ស** ...... ១៨

**៣.៣ ការផ្សព្វផ្សាយ និងការបង្ការហានិភ័យការងារ** ...... ២៥

## ជំពូកទី២

## ការអនុវត្តសំណងគ្រោះថ្នាក់ការងារ

**ផ្នែកទី១៖ លទ្ធិផលសំណងឆ្នាំ២០០៨-២០១៧** .......... ២៨

**១.១ ការទទួលគ្រោះថ្នាក់ដល់ស្លាប់** .......... ២៩

**១.២ ឧត្តរជីវី** .......... ២៩

១.២.១ លក្ខខណ្ឌដែលត្រូវទទួលបានតាវកាលិកឧត្តរជីវី សិទ្ធិវន្តរបស់សមាជិក ប.ស.ស .......... ២៩

១.២.២ តាវកាលិកឧត្តរជីវី .......... ៣០

**ផ្នែកទី២៖ បញ្ហាប្រឈម** .......... ៣១

**២.១. បញ្ហាប្រឈមការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ** .......... ៣១

២.១.១ បញ្ហាប្រឈមលើការពង្រឹង និងពង្រីកការអនុវត្តហានិភ័យការងារ .......... ៣១

២.១.២ បញ្ហាប្រឈមលើការពង្រឹង និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព .......... ៣២

២.១.៣ បញ្ហាប្រឈមលើការជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកសោធន .......... ៣២

**២.២. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន** .......... ៣៣

**២.៣. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករ និយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រី នៅពេលសម្រាលកូន** .......... ៣៣

**២.៤. ការងារគាំទ្រការអនុវត្ត** .......... ៣៣

**ផ្នែកទី៣៖ ដំណោះស្រាយ និងទិសដៅអនុវត្តបន្ត** .......... ៣៤

**៣.១. ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោម បទបញ្ញត្តិនៃច្បាប់ស្តីពីការងារ** .......... ៣៤

៣.១.១ ការពង្រឹង និងពង្រីកការអនុវត្តហានិភ័យការងារ .......... ៣៤

៣.១.២ ការពង្រឹង និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព .......... ៣៥

៣.១.៣ ការជម្រុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកសោធន .......... ៣៥

៣.២.ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការនិង អតីតយុទ្ធជន ........ ៣៥
៣.៣. ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករ និយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ ឧបត្ថម្ភបន្ថែមសម្រាប់ កម្មករនិយោជិតជាស្ត្រី នៅពេលសម្រាលកូន ........ ៣៦
សេចក្តីសន្និដ្ឋាន ........ ៣៨
អនុសាសន៍ ........ ៣៩
ឯកសារយោង
ឧបសម្ព័ន្ធ

# អក្សរកាត់

| | |
|---|---|
| កបក | កម្រិតនៃការបាត់បង់សមត្ថភាពរបស់ជនរងគ្រោះ |
| ទ.ស.ប.ក | ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ |
| ធល | ធនលាភសម្រាប់បាត់បង់សមត្ថភាព |
| បឈម | ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ |
| ប.ស.ស | បេឡាជាតិរបបសន្តិសុខសង្គម |
| ប.ផ.ក | បង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត |
| មតប | មេគុណតម្លៃបច្ចុប្បន្ន |
| វបក | វិភាជន៍ចាត់បង់សមត្ថភាពការងារ |
| ILO | អង្គការអន្តរជាតិខាងការងារ (International Labor Organization) |

# សេចក្តីផ្តើម

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់ស្តីពីការងារ និងអនុក្រឹត្យស្តីពីការបង្កើត ប.ស.ស ដោយស្របតាមយុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្រអភិវឌ្ឍជាតិ យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

អនុលោមតាមច្បាប់ និងផែនការយុទ្ធសាស្ត្រខាងលើ ប.ស.ស បានដាក់ផែនការអនុវត្តជំហានទី១ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ព្រមទាំងទទួលបានការគាំទ្រទាំងនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ។

ក្នុងរយៈពេល ១០ឆ្នាំដោយគិតចាប់ពីឆ្នាំ២០០៨ ដល់ដំណាច់ឆ្នាំ២០១៧ ការដាក់ឱ្យដំណើរការជំហានទី១ ផ្នែកហានិភ័យការងារ ដែលទទួលបានជោគជ័យនេះ ជាចលករដ៏សំខាន់មួយទៀតក្នុងការជួយជម្រុញឱ្យ ប.ស.ស អនុវត្តជំហានទី២ ផ្នែកថែទាំសុខភាព ដល់កម្មករនិយោជិត។ ទន្ទឹមនឹងភាពជោគជ័យ ប.ស.ស ក៏បានរកឃើញបញ្ហាមួយចំនួនទាំងចំណុចខ្លាំង និងចំណុចខ្សោយ ដែលជាបទពិសោធន៍ដ៏មានសារៈសំខាន់មួយទៀតសម្រាប់ ធ្វើឱ្យប្រសើរឡើងការអនុវត្តជំហានទី១ និងការអនុវត្តជំហានទី២ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជូនកម្មករនិយោជិត ក្នុងទិសដៅលើកកម្ពស់សុខភាពកម្មករនិយោជិត និងជំហានទី៣ ផ្នែកប្រាក់សោធន ដែលនឹងដាក់ឱ្យអនុវត្តក្នុងពេលដ៏ខ្លីខាងមុខនេះ។

ដើម្បីលើកកម្ពស់សុខុមាលភាពសង្គមឱ្យបានកាន់តែប្រសើរ និងធានាសង្គតិភាពក្នុងការគាំពារផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពឱ្យកម្មករនិយោជិតក្នុងវិស័យឯកជន និងមានការផ្តល់ទំនុកចិត្ត សេចក្តីជឿជាក់ទាំងស្រុងចំពោះសមិទ្ធផលកន្លងមករបស់ប.ស.ស រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចថ្មីក្នុងការអនុវត្តរបបសន្តិសុខសង្គម តាមរយៈព្រះរាជក្រឹត្យ នស/រកត/០៣១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់ថែទាំសុខភាព។

# ជំពូកទី១

# សញ្ញាណទូទៅ និងលទ្ធផលការងារ

## ផ្នែកទី១៖ និយមន័យបេឡាជាតិរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈដែលត្រូវបានបង្កើត ដោយអនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ [1] ឬជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយដែលមានបេសកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម[2]។

ប.ស.ស គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។[3] ហើយ ប.ស.ស មានបុព្វសិទ្ធិអំណាចសាធារណៈ ក្នុងការប្រមូលចំណូលការឱ្យសងបំណុល និងការពារទ្រព្យសម្បត្តិ។[4] បុព្វសិទ្ធិនេះអាចអនុវត្តនៅពេលដែលសហគ្រាស គ្រឹះស្ថានក្ស័យធន ឬត្រូវបានជម្រះបញ្ជីដោយតុលាការបន្ទាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រមរបស់តុលាការ។[5] នីតិវិធីនៃការទារបំណុលរបស់ ប.ស.ស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[6]

លើសពីនេះទៅទៀត ប.ស.ស ជាបណ្តុំនៃវិធានរៀបចំឡើងសម្រាប់ធានាកម្មករនិយោជិត និងគ្រួសាររបស់ពួកគេ ដែលមានបញ្ហាហានិភ័យសង្គមដូចជា គ្រោះថ្នាក់ការងារ ជម្ងឺវិជ្ជាជីវៈ ប្រាក់សោធន និងភាពគ្មានការងារធ្វើព្រមទាំងជម្ងឺផ្សេងៗ ជរាភាព ទុព្វលភាព និងមរណភាពជាដើម។ ម្យ៉ាងវិញទៀតគេអាចហៅ ប.ស.ស ថាជាអង្គការ ឬ ស្ថាប័នមួយដែលទទួលបន្ទុកអនុវត្តនូវវិធាននៃរបបសន្តិសុខសង្គម។[7] បេឡាជាតិរបបសន្តិសុខសង្គម គឺជាអ្នកផ្តល់សេវាសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[8]

[1] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២ មាត្រា៣

[2] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម លេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០០៧ មាត្រា១

[3] ហេង លីណា ស្តីពីនីតិការងារ និងនីតិនិរភ័យការងារ ឆ្នាំ២០១៦-២០១៧ ទំព័រទី១៣

[4] ហេង លីណា ស្តីពីនីតិការងារ និងនីតិនិរភ័យការងារ ឆ្នាំ២០១៦-២០១៧ ទំព័រទី១៣

[5] ហេង លីណា ស្តីពីនីតិការងារ និងនីតិនិរភ័យការងារ ឆ្នាំ២០១៦-២០១៧ ទំព័រទី១៣

[6] ហេង លីណា ស្តីពីនីតិការងារ និងនីតិនិរភ័យការងារ ឆ្នាំ២០១៦-២០១៧ ទំព័រទី១៣

[7] Brigitte Hess Fallon Anne Marie Simon , Droit du trabail et de la Securite Sociale ( បារាំង, ១៩៩៨)

[8] ហេង លីណា ស្តីពីនីតិការងារ និងនីតិនិរភ័យការងារ ឆ្នាំ២០១៦-២០១៧ ទំព័រទី៥

## ១.១.ប្រវត្តិបេឡាជាតិរបបសន្តិសុខសង្គម

របបសន្តិសុខសង្គមត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៥៥ យោងតាមព្រះរាជក្រឹត្យលេខ៥៥ និង៣០៦។ តែគួរឱ្យសោកស្តាយកំឡុងពេលរបបប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩) សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង។[9] ពីឆ្នាំ១៩៧៩-១៩៩៣ ប្រជាជនបានទទួល សេវាថែទាំសុខភាពដោយឥតគិតថ្លៃ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិ-សុខសង្គមត្រូវបានបង្កើតឡើង។ នាយកដ្ឋាននេះទទួលខុសត្រូវនៅការរៀបចំទាំងអស់នៃប្រកាសសម្រាប់ ការអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជន ដែលធ្វើការក្នុងវិស័យឯកជន។ ជាលទ្ធផល ការកែប្រែបទប្បញ្ញត្តិស្តីពីច្បាប់ការងារឆ្នាំ១៩៩២ ដែលជាច្បាប់ការងារកម្ពុជា បច្ចុប្បន្នដែលអនុម័តក្នុងឆ្នាំ១៩៩៧ ត្រូវបានអនុវត្តដោយនាយកដ្ឋានការងារ (ថ្មីៗនេះប្តូរទៅជាអគ្គនាយកដ្ឋានការងារ)។[10] បន្ទាប់ពីនោះមក ច្បាប់សន្តិសុខសង្គម ត្រូវបានអនុម័តដោយសភានៅខែកញ្ញា ឆ្នាំ ២០០២ ដែលថ្មីៗត្រូវបានគេស្គាល់ថា ច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានអនុម័ត នៅឆ្នាំ២០០៧ ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ ប.ស.ស ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផ្នែកកិច្ចគាំពារ សន្តិសុខសង្គមឱ្យស្របទៅតាមច្បាប់សន្តិសុខសង្គមជាតិ និងបទប្បញ្ញត្តិសន្តិសុខសង្គមអនុលោមតាមអនុក្រឹត្យ។ ក្រោយពីការរៀបចំដ៏ធំទូលាយនេះប.ស.ស ត្រូវបានដំណើរការនៅចុងឆ្នាំ២០០៨ ។ កម្មករនិយោជិតនឹងទទួលបានសំណងការខូចខាតពីបេឡាជាតិរបបសន្តិសង្គម ដោយមិនមានការរើសអើង អ្នកមាន ឬអ្នកក្រ ពណ៌ស ឬពណ៌ខ្មៅ ព្រមទាំងជាតិសាសន៍អ្វីឡើយ។[11]

អនុលោមតាមច្បាប់ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ និងការធ្វើសមាហរណកម្មក្នុងតំបន់ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងត្រៀមខ្លួនតាមរយៈការរៀបចំពង្រីក ពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដោយបានរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំនេះឡើងដែលមានចក្ខុវិស័យ និងបេសកកម្មដ៏ច្បាស់លាស់ក្នុងការអនុវត្តផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យទទួលបាននូវសេវាសន្តិសុខសង្គម នៅពេលដែលពួកគាត់ជួបប្រទះនូវយថាភាពផ្សេងៗ មានជាអាទិ៍ ជរាភាព

[9] ប៊ូយ ធីតា មុខវិជ្ជានីតិការងារ ឆ្នាំសិក្សា ២០១២-២០១៣ ទំព័រទី១

[10] ប៊ូយ ធីតា មុខវិជ្ជានីតិការងារ ឆ្នាំសិក្សា ២០១២-២០១៣ ទំព័រទី១

[11] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣, មាត្រា៣១

ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និងមាតុភាពជាដើម។

ក្នុងស្ថានភាពដែលប្រទេសកម្ពុជាមានការរីកចំរើនលើគ្រប់វិស័យ ការធានាផ្នែកសន្តិសុខសង្គមមានសារៈសំខាន់ខ្លាំងណាស់ដោយបានផ្តល់នូវការគាំពារចំពោះប្រជាជនកម្ពុជា និយាយជារួម និងនិយាយដោយឡែក សម្រាប់កម្មករនិយោជិតដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើទស្សនាទាននៃការចែករំលែក និងគោលការណ៍សាមគ្គីធម៌ក្នុងសង្គមធានាបាននូវសន្តិសុខប្រាក់ចំណូល ពោលគឺមានន័យថា តាមរយៈការធានាផ្នែកសន្តិសុខសង្គមគ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យនៃភាពក្រីក្រ ដោយមិនអាចងើបរួចបានឡើយ។ម្យ៉ាងទៀតគោលនយោបាយសន្តិសុខសង្គម ក៏រួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលការណ៍នៃការចែករំលែកប្រាក់ចំណូល តាមខ្សែទទឹង និងខ្សែបណ្តោយ គឺមានន័យថា អ្នកមានប្រាក់ចំណូលខ្ពស់ជួយដល់អ្នកមានប្រាក់ចំណូលទាប អ្នកមានសុខភាពល្អ ជួយដល់អ្នកមានជំងឺ ជនពិការ ឬអ្នកដែលទទួលរងនូវគ្រោះថ្នាក់ផ្សេងៗ ជនមានវ័យក្មេងជួយដល់ជនចាស់ជរា ដែលការនេះធ្វើឱ្យមនុស្សក្នុងសង្គមទាំងមូល ទទួលបាននូវភាពកក់ក្តៅក្នុងជីវភាពរស់នៅ ធានារក្សាបានស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។[12]

ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ដោយការធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម ប.ស.ស បានអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនគ្រោងអនុវត្តនៅពេលឆាប់ៗខាងមុខនេះ។ ឈរលើការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពប្រកបដោយជោគជ័យ និងធានាឱ្យមានភាពសង្គតិភាពក្នុងការគាំពារសង្គមក្នុងវិស័យឯកជន ។

## ១.២.តួនាទី និងរចនាសម្ព័ន្ធ

### ១.២.១ តួនាទី

- គ្រប់គ្រងរបបសន្តិសុខសង្គមដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ។

[12] បេឡាជាតិរបបសន្តិសុខសង្គម http://www.nssf.gov.kh/default ចូលមើលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨

- ធានាផ្តល់ឱ្យបានសមស្របតាវកាលិកទាំងឡាយដល់សមាជិករបស់ខ្លួន នៅក្នុងគោលបំណងជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យ-ការងារ ឬជួបប្រទះយថាភាពផ្សេងៗទៀតដូចជា ជម្ងឺ និងការសម្រាកមាតុភាពជាដើម។
- ប្រមូលភាគទានពីសមាជិកបេឡាជាតិរបបសន្តិសុខសង្គម និងនិយោជក។
- សម្របសម្រួល និងធ្វើការរៀបចំឱ្យមានសេវាសុខាភិបាល និងសង្គមកិច្ចសម្រាប់ប្រ-យោជន៍ដល់សមាជិក
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី អប់រំផ្សព្វផ្សាយអំពី របៀបបង្ការគ្រោះថ្នាក់ការងារ ជម្ងឺវិជ្ជាជីវៈ ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ អនាម័យ ការងារ សិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។[13]

**១.២.២ រចនាសម្ព័ន្ធ**

បេឡាជាតិរបបសន្តិសុខសង្គម ដែលហៅកាត់ថា ប.ស.ស ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមួយ និងអាណាព្យាបាលបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[14]

រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គមមានដូចខាងក្រោមៈ[15]

- ការិយាល័យរដ្ឋបាល
- ការិយាល័យហិរញ្ញវត្ថុ និងកិច្ចការគណនេយ្យ
- ការិយាល័យសវនកម្មផ្ទៃក្នុង
- ការិយាល័យអធិការកិច្ច និងកិច្ចការនីតិកម្ម
- ការិយាល័យពត៌មានវិទ្យា
- ការិយាល័យបញ្ជិកា និងភាគទាន
- ការិយាល័យតាវកាលិក
- ការិយាល័យគោលនយោបាយ

[13] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម លេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០០៧ មាត្រា៣

[14] ប្រកាសស្តីពី រចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គម,លេខ ២៨៧ បក/ប្រ.ក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ ប្រការ១

[15] ប្រកាសស្តីពី រចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គមលេខ ២៨៧ បក/ប្រ.ក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ ប្រការ២

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានយ៉ាងច្រើន ០២ រូបជាជំនួយការ ។

បេឡាជាតិរបបសន្តិសុខសង្គមអាចនឹងរៀបចំការិយាល័យសាខាតាមខេត្តក្រុងតាមស្ថានភាពជាក់ស្តែង។[16]

## ផ្នែកទី២៖ លទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០០៨-២០១៧

### ២.១. ការអនុវត្តរបបសន្តិសុខសង្គមលើហានិភ័យការងារ

#### ២.១.១ បញ្ជិកា និងភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាន និងបង់ភាគទានហានិភ័យការងារមកក្នុងប.ស.ស។[17] ក្នុងដំណាក់កាលចាប់ដំណើរការដំបូងនៃ ប.ស.ស ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែរមានកម្មករនិយោជិកធ្វើការជាប់លាប់តិចជាង ៨នាក់ ហើយគ្មានប្រើប្រាស់គ្រឿងយន្ត ត្រូវធ្វើសេចក្តីជូនដំណឹងអំពីការបើក សហគ្រាស គ្រឹះស្ថាន ទៅក្រសួងទទួលបន្ទុកវិស័យការងារក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃបើក សហគ្រាស គ្រឹះស្ថានជាស្ថាពរ។[18] អត្រាភាគទានហានិភ័យការងារជាអត្រាឯកភាពដែរត្រូវបានកំណត់ស្មើរនឹង ០,៨ភាគរយ នៃប្រាក់ឈ្នួលមធ្យម ក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។[19]

##### ក. ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

ចាប់តាំងពីដំណើរការដំបូងនៃ ខែវិច្ឆិកា ឆ្នាំ ២០០៨ រហូតមកដល់ឆ្នាំ ២០១៧នេះ ប.ស.ស បានពង្រីកវិសាលភាពផ្នែកហានិភ័យការងារ គ្របដណ្តាប់នូវទូទាំងប្រទេស និងបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សរុបចំនួន ១០៨៤៩ សហគ្រាស មានកម្មករនិយោជិត សរុបចំនួន ១៤៣៥៣១៦នាក់ ស្រី ចំនួន ៨៦៨១៨៦នាក់ ត្រូវជា ៦០,៤៨ភាគរយ។[20]

[16] ប្រកាសស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គម លេខ២៨៧ បក/ប្រ.កចុះថ្ងៃទី២៧ខែវិច្ឆិកាឆ្នាំ ២០០៨ ប្រការ២

ប្រកាសស្តីពី បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកាឆ្នាំ២០១៧ ប្រការ ៥

[18] ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧ មាត្រា ១៧

[19] បេឡាជាតិរបបសន្តិសុខសង្គម, (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២

[20] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២

*តារាងទី១. សហគ្រាសចុះបញ្ជិកា និងសមាជិកសរុប[21]*

| សហគ្រាស ចុះបញ្ជិកា និងសមាជិកសរុប | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សហគ្រាស ចុះបញ្ជិកា និងសមាជិកសរុប | | | សហគ្រាស ចុះបញ្ជិកា និងសមាជិក | | | ថ្នាក់កណ្ដាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2008- ឆ្នាំ2017 | 10,849 | 1,435,316 | 868,186 | 2,118 | 299,045 | 70,159 | 909 | 44,405 | 20,561 | 1,209 | 254,640 | 49,598 |
| ឆ្នាំ2008- ឆ្នាំ2016 | 8,731 | 1,136,271 | 798,027 | 935 | 59,192 | 36,014 | 426 | 24,969 | 14,425 | 509 | 34,223 | 21,589 |
| ឆ្នាំ2008- ឆ្នាំ2015 | 7,796 | 1,077,079 | 762,013 | 755 | 55,491 | 36,686 | 388 | 31,426 | 20,640 | 367 | 24,065 | 16,046 |
| ឆ្នាំ2008- ឆ្នាំ2014 | 7,041 | 1,021,588 | 725,327 | 934 | 174,413 | 125,605 | 576 | 88,195 | 55,470 | 358 | 86,218 | 70,135 |
| ឆ្នាំ2008- ឆ្នាំ2013 | 6,107 | 847,175 | 599,722 | 1,524 | 79,041 | 56,119 | 840 | 34,166 | 19,457 | 684 | 44,875 | 36,662 |
| ឆ្នាំ2008- ឆ្នាំ2012 | 4,583 | 768,134 | 543,603 | 1,478 | 93,917 | 66,681 | 595 | 30,811 | 20,136 | 883 | 63,106 | 46,545 |
| ឆ្នាំ2008- ឆ្នាំ2011 | 3,105 | 674,217 | 476,922 | 1,195 | 79,531 | 56,864 | 844 | 41,515 | 29,574 | 351 | 38,016 | 27,290 |
| ឆ្នាំ2008- ឆ្នាំ2010 | 1,910 | 594,686 | 420,058 | 927 | 143,454 | 101,852 | 550 | 71,827 | 46,172 | 377 | 71,627 | 55,680 |
| ឆ្នាំ2008- ឆ្នាំ2009 | 983 | 451,232 | 318,206 | 656 | 387,046 | 279,695 | 567 | 259,411 | 190,370 | 89 | 127,635 | 89,325 |
| ឆ្នាំ2008 | 327 | 64,186 | 38,511 | 327 | 64,186 | 38,511 | 327 | 64,186 | 38,511 | 0 | 0 | 0 |

*តារាងទី២. បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត[22]*

| បច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | ថ្នាក់កណ្ដាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2017 | 8,507 | 1,182,849 | 787,547 | 4,435 | 627,637 | 389,029 | 4,072 | 555,212 | 398,518 |
| ឆ្នាំ2016 | 6,884 | 1,108,759 | 752,459 | 3,832 | 611,064 | 396,987 | 3,052 | 497,695 | 355,472 |
| បម្រែបម្រួល( %) | 23.58% | 6.68% | 4.66% | 15.74% | 2.71% | -2.00% | 33.42% | 11.56% | 12.11% |

*តារាងទី៣៖ បច្ចុប្បន្នភាព សហគ្រាសវិស័យកាត់ដេរ និងផលិតស្បែកជើងថ្នាក់កណ្ដាល -ថ្នាក់ខេត្ត[23]*

| សហគ្រាសវិស័យកាតដេរ និងផលិតស្បែក ជើង ថ្នាក់កណ្ដាល-ថ្នាក់ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | ថ្នាក់កណ្ដាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2017 | 1,021 | 696,554 | 576,772 | 626 | 341,023 | 279,441 | 395 | 355,531 | 297,331 |
| ឆ្នាំ2016 | 1,006 | 687,686 | 566,645 | 646 | 362,001 | 298,371 | 360 | 325,685 | 268,274 |
| បម្រែបម្រួល( %) | 1.49% | 1.29% | 1.79% | -3.10% | -5.80% | -6.34% | 9.72% | 9.16% | 10.83% |

## ខ. ប្រភេទសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជី

ចាប់ពីឆ្នាំ២០០៨ ដល់ដំណាច់ឆ្នាំ២០១៧នេះ ប.ស.ស បានទទួលបញ្ជិកាសហគ្រាគ្រឹះស្ថាន ចំនួន ១០៨៤៩ ក្នុងនោះវិស័យកាត់ដេរ ចំនួន ៦៩៩២ វិស័យសណ្ឋាគារមាន ចំនួន៣៩៩ បម្រើសេ

[21] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៣
[22] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៣
[23] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៣

វាកម្មផ្សេងៗចំនួន ២១២ ភោជនីយដ្ឋាន ចំនួន២១៩ អង្គការចំនួន ១៦២ និងសហគ្រាសផ្សេងៗទៀតចំនួន ៣៣៦៥។[24]

### គ. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ

*តារាងទី៤. សហគ្រាសបិទទ្វារ និងផ្អាកដំណើរការ ថ្នាក់កណ្ដាល -ថ្នាក់ខេត្ត*[25]

| សហគ្រាស បិទទ្វារ និងផ្អាក ដំណើរការ ថ្នាក់កណ្ដាល -ថ្នាក់ ខេត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | បិទទ្វារ | | | ផ្អាកដំណើរការ | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ឆ្នាំ2008-ឆ្នាំ2017 | 2,342 | 252,467 | 80,639 | 2,241 | 244,178 | 77,090 | 101 | 8,289 | 3,549 |

ជាការគួរឱ្យកត់សម្គាល់ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន ដែលបានឈប់ដំណើរការខាងលើរហូតមកដល់ពេលនេះមានសហគ្រាសគ្រឹះស្ថាន មួយចំនួនបានបើកដំណើរការវិញហើយដែលក្នុងនោះមួយចំនួនបានប្តូរឈ្មោះ មួយចំនួនទៀតបានប្តូរម្ចាស់ ដែលភាគច្រើនជាសិប្បកម្ម ឡឥដ្ឋ ភោជនីយដ្ឋាន... ដែលមានទីតាំងនៅឆ្ងាយ។[26]

### ឃ. ការងារភាគទាន

ក្នុងចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ដែលបានចុះបញ្ជិកាបេឡាជាតិរបបសន្តិសុខសង្គម ដែលបានដាក់ឱ្យជាប់ភាគទានពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៧ មានដូចខាងក្រោម៖[27]

[24] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៤

[25] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៤

[26] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៤

[27] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៥

*តារាងទី៥. សហគ្រាស គ្រឹះស្ថាន សរុបបានបង់ភាគទាន*

| សហគ្រាស គ្រឹះស្ថាន សរុបបានបង់ភាគទាន | | | | | | |
|---|---|---|---|---|---|---|
| បរិយាយ | សហគ្រាស ជាប់ភាគទាន (មធ្យមភាគ) | សហគ្រាស បានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | | ភាគទាន (ប៊ីលានរៀល ) | ភាគរយសហគ្រាស បានបង់ភាគទាន |
| | | | សរុប | ស្រី | | |
| ឆ្នាំ2017 | 6,866 | 6,104 | 1,156,675 | 793,085 | 91.88 | 89% |
| ឆ្នាំ2016 | 6,618 | 5,416 | 1,042,143 | 723,312 | 82.7 | 82% |
| ឆ្នាំ2015 | 6,140 | 5,622 | 1,038,151 | 726,705 | 74.33 | 92% |
| ឆ្នាំ2014 | 5,758 | 4,966 | 908,535 | 635,975 | 57.29 | 86% |
| ឆ្នាំ2013 | 4,749 | 4,577 | 824,011 | 576,808 | 43.14 | 96% |
| ឆ្នាំ2012 | 3,886 | 3,459 | 694,199 | 478,998 | 30.48 | 89% |
| ឆ្នាំ2011 | 2,450 | 2,182 | 573,023 | 395,386 | 24.31 | 89% |
| ឆ្នាំ2010 | 1,608 | 1,444 | 481,010 | 331,897 | 14.37 | 90% |
| ឆ្នាំ2009 | 605 | 553 | 317,224 | 222,057 | 8.02 | 91% |
| ឆ្នាំ2008 | 322 | 301 | 256,316 | 176,858 | 1.47 | 93% |
| សរុបភាគទាន | | | | | 427.98 | |

### ២.១.២ អធិការកិច្ច និងនីតិកម្ម

ការងារអធិការកិច្ច និងកិច្ចការនីតិកម្ម មានមុខងារក្នុងការធានាឱ្យមានការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗជាធរមាន។ [28] ផ្នែកនេះផ្តោតជាសំខាន់ លើការងារមួយចំនួនមានជាអាទិ៍ ការចុះពន្យល់ ណែនាំម្ចាស់សហគ្រាស គ្រឹះស្ថាន ស្តីពីការអនុវត្តគោលនយោបាយអនុវត្តរបបសន្តិសុខសង្គម ដើម្បីឱ្យមានការចុះបញ្ជិកា និងការបង់ភាគទាននៅ ប.ស.ស ការចុះអង្កេតគ្រោះថ្នាក់ការងារ ការអង្កេតអំពីស្ថានភាពរបស់អ្នករស់នៅក្នុងបន្ទប់របស់ជនរងគ្រោះ ការពង្រឹងការអនុវត្តច្បាប់ តាមរយៈការធ្វើអធិការកិច្ចការដាក់កំហិត ការពិន័យ ការដាក់បណ្តឹងទៅតុលាការ ក្នុងករណីសហគ្រាស គ្រឹះស្ថានមិនព្រមអនុវត្តច្បាប់។[29]

លទ្ធផលចុះអធិការកិច្ច ឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៧ សរុបចំនួន ១៦៥០៧លើក ស្មើនឹង ៦៣ ៥៧៣( ដងសហគ្រាស) ក្នុងនោះការដាក់ពិន័យមិនព្រមចុះបញ្ជិកា ចំនួន ៩០១សហគ្រាស និងមិនបង់ភាគទានចំនួន ២១៧ សហគ្រាស។[30]

[28] ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ មាត្រា ៣៩៤

[29] ច្បាប់ស្តីពីការងារ ជស/រកម/០៣៩៧/០១ ១៣ មិនា ១៩៩៧ មាត្រា៣៩៧

[30] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៦

### ក. អធិការ

*តារាងទី៦. ការងារអធិការកិច្ច*[31]

| ការងារអធិការកិច្ច | | | | |
|---|---|---|---|---|
| បរិយាយ | ការចុះអធិការកិច្ច ចុះបញ្ជិកា | ការចុះអធិការកិច្ច ការងារតែមួយ | ការចុះអធិការកិច្ច ទារភាគទាន | ការងារ ផ្សេងៗ ផ្នែកអធិការកិច្ច |
| | ដងសហគ្រាស | ដងសហគ្រាស | ដងសហគ្រាស | ដងសហគ្រាស |
| ឆ្នាំ2017 | 2,193 | 284 | 490 | 14,766 |
| ឆ្នាំ2016 | 2,648 | 1,381 | 695 | 1,588 |
| ឆ្នាំ2015 | 3,384 | 1,697 | 311 | 1,016 |
| ឆ្នាំ2014 | 2,501 | 1,844 | 680 | 1,306 |
| ឆ្នាំ2013 | 9,087 | - | 292 | 1,350 |
| ឆ្នាំ2012 | 3,732 | - | 1,434 | 336 |
| ឆ្នាំ2011 | 3,556 | - | 191 | 1,762 |
| ឆ្នាំ2010 | 2,265 | - | 67 | 623 |
| ឆ្នាំ2009 | 705 | - | 43 | 1,346 |
| ឆ្នាំ2008 | _ | - | _ | _ |
| សរុប | 30,071 | 5,206 | 4,203 | 24,093 |

### ខ. នីតិកម្ម

បានចុះធ្វើការផាកពិន័យការចុះបញ្ជិកា សហគ្រាស គ្រឹះស្ថាន ចំនួន ៦៣៥ សហគ្រាស ផាកពិន័យមិនបង់ភាគទានសហគ្រាស គ្រឹះឋានស្ថានចំនួន ២១៧ សហគ្រាស និងបន្តតាមដាននីតិវិធីតាមផ្លូវច្បាប់ចំពោះសហគ្រាស គ្រឹះស្ថានចំនួន៤៩ ដែលបានប្ដឹងទៅសាលាដំបូងរាជធានី ដែលមានកំហុសទាក់ទង និងការរាយការណ៍ចំនួនកម្មករនិយោជិតមក ប.ស.ស មិនត្រឹមត្រូវ ការប្រកាសប្រាក់ឈ្នួលមិនត្រឹមត្រូវ ការមិនបង់ភាគទាន ការជំទាស់នឹងការអនុវត្តមុខងារអធិការ ប.ស.ស ព្រមទាំងពិន័យផ្សេងៗទៀតជាដើម។[32]

### ២.១.៣ តាវកាលិក

ថ្វីត្បិតចំនួនគ្រោះថ្នាក់ការងារបានបន្តកើតមានជាបន្តបន្ទាប់ក្ដីក៏ដោយ ប.ស.ស បានរៀបចំអភិវឌ្ឍបែបបទការងារ និងបានពង្រីកយន្តការនៃការផ្ដល់តាវកាលិកឱ្យកាន់តែមានភាពងាយស្រួលទំលំទូលាយបន្ថែមទៀត ដើម្បីអោយកម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ការងារទទួលបាន

31 បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៦

32 បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រ៦

សេវាប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។[33] តាមរយៈនេះ ប.ស.ស បានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវ ប្រព័ន្ធទិន្នន័យទាមទារ តាវកាលិកហានិភ័យការងារ ដែលប្រព័ន្ធនេះអាចគ្រប់គ្រងបាននូវរបាយការណ៍ការហានិភ័យការងារ ការអង្កេត និងការគណនាតាវកាលិក ដែលវាបានពន្លឿនក្នុងការផ្តល់តាវកាលិក និងមានភាពត្រឹមត្រូវ។ ប.ស.ស ក៏បានពង្រីកការចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសាធារណៈ និងឯកជនចំនួន ១២២ មូលដ្ឋាន និងបានដាក់ភ្នាក់ងារឱ្យប្រចាំការនៅមន្ទីរពេទ្យបានមួយចំនួន សម្រាប់ជួយសម្របសម្រួលដល់ជនរងគ្រោះ ដែលជាសមាជិករបស់ ប.ស.ស ឱ្យទទួលបានការសម្រាក់ព្យាបាល និងងាយស្រួលទទួលបានសេវានៅកន្លែងដែលជិត។ មួយវិញទៀតក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប.ស.ស បានបញ្ជូនមន្ត្រីទៅកន្លែងគ្រោះថ្នាក់ផ្ទាល់ដើម្បី ជួយសម្របសម្រួល និងធ្វើអន្តរាគមន៍ទាន់ពេលវេលា។[34]

### ក. របាយការណ៍ហានិភ័យការងារ

ចាប់ពីឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៧នេះ ប.ស.ស បានទទួលរបាយការណ៍ហានិភ័យការងារបន្តពីសហគ្រាស គ្រឹះស្ថាន តាមបន្ត រាជធានី ខេត្ត នៅទូទាំងប្រទេស។[35]

[33] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៦
[34] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៦
[35] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៧

*តារាងទី៧. ស្ថានភាពហានិភ័យការងារ*[36]

| ស្ថានភាពហានិភ័យការងារ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិយាយ | ស្ថានភាពរបាយការណ៍ហានិភ័យការងារ | | | | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | | |
| | ទទួលរបាការណ៍ហានិភ័យការងារ(នាក់) | | សមាជិកសរុប | ផលធៀប | សរុប | | ស្រាល | | ធ្ងន់ | | ស្លាប់ | | |
| | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2017 | 47,496 | 36,024 | 1,436,316 | 3.31% | 45,882 | 34,773 | 42,716 | 33,029 | 2,944 | 1,671 | 222 | 73 |
| ឆ្នាំ2016 | 36,734 | 27,338 | 1,136,271 | 3.23% | 34,513 | 25,683 | 31,899 | 24,162 | 2,446 | 1,461 | 168 | 60 |
| ឆ្នាំ2015 | 30,919 | 22,764 | 1,077,079 | 2.87% | 30,281 | 22,273 | 27,804 | 20,802 | 2,296 | 1,404 | 181 | 67 |
| ឆ្នាំ2014 | 19,425 | 14,410 | 1,021,588 | 1.90% | 18,699 | 13,820 | 17,216 | 13,003 | 1,387 | 790 | 96 | 27 |
| ឆ្នាំ2013 | 16,849 | 12,034 | 847,175 | 1.99% | 16,775 | 12,030 | 15,452 | 11,310 | 1,227 | 690 | 96 | 30 |
| ឆ្នាំ2012 | 14,761 | 11,023 | 768,134 | 1.92% | 14,233 | 10,709 | 13,603 | 10,354 | 571 | 333 | 59 | 22 |
| ឆ្នាំ2011 | 13,167 | 10276 | 674,217 | 1.95% | 12,571 | 9,734 | 12,084 | 9,492 | 440 | 227 | 47 | 15 |
| ឆ្នាំ2010 | 8,498 | 6,644 | 594,686 | 1.43% | 7,611 | 5,878 | 7,214 | 5,652 | 358 | 206 | 39 | 20 |
| ឆ្នាំ2009 | 3,792 | 3,072 | 451,232 | 0.84% | 3,547 | 2,872 | 3,355 | 2,754 | 176 | 108 | 16 | 10 |
| ឆ្នាំ2008 | N/A | N/A | N/A | N/A | 107 | 78 | 91 | 65 | 15 | 12 | 1 | 1 |
| សរុប 2008-2017 | 191,641 | 143,585 | | | 184,219 | 137,850 | 171,434 | 130,623 | 11,860 | 6,902 | 925 | 325 |

*តារាងទី៨. លទ្ធផលអង្កេតហានិភ័យការងារ (ប្រភេទគ្រោះថ្នាក់)*[37]

| លទ្ធផលអង្កេតហានិភ័យការងារ (ប្រភេទគ្រោះថ្នាក់) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បរិយាយ | លទ្ធផលអង្កេតហានិភ័យការងារ (នាក់) | | | | | | | |
| | សរុប | | គ្រោះថ្នាក់កន្លែងធ្វើការ | | គ្រោះថ្នាក់ពេលធ្វើដំណើរ | | ជម្ងឺវិជ្ជាជីវៈ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ឆ្នាំ2017 | 45,882 | 34,773 | 34,567 | 27,736 | 11,300 | 7,024 | 15 | 13 |
| ឆ្នាំ2016 | 34,513 | 25,683 | 24,902 | 19,477 | 9,608 | 6,204 | 3 | 2 |
| ឆ្នាំ2015 | 30,281 | 22,273 | 22,487 | 17,280 | 7,791 | 4,991 | 3 | 2 |
| ឆ្នាំ2014 | 18,699 | 13,820 | 14,022 | 10,896 | 4,674 | 2,923 | 3 | 1 |
| ឆ្នាំ2013 | 16,775 | 12,030 | 12,060 | 9,007 | 4,703 | 3,015 | 12 | 8 |
| ឆ្នាំ2012 | 14,233 | 10,709 | 10,573 | 8,342 | 3,642 | 2,357 | 18 | 10 |
| ឆ្នាំ2011 | 12,571 | 9,734 | 9,006 | 7,386 | 3,565 | 2,348 | - | - |
| ឆ្នាំ2010 | 7,611 | 5,878 | 5,109 | 3,946 | 2,502 | 1,932 | - | - |
| ឆ្នាំ2009 | 3,547 | 2,872 | 2,523 | 2,043 | 1,024 | 829 | - | - |
| ឆ្នាំ2008 | 107 | 78 | 56 | 50 | 51 | 28 | - | - |
| សរុប 2008-2017 | 184,219 | 137,850 | 135,305 | 106,163 | 48,860 | 31,651 | 54 | 36 |

[36] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ, លេខទំព័រទី៧
[37] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៨

### ខ. ការចំណាយតាមប្រភេទតាវកាលិក

តាមរយៈការទាមទារតាវកាលិកពីជនរងគ្រោះ ប.ស.ស បានចេញសេចក្តីសម្រេចផ្តល់តាវកាលិកហានិភ័យការងារ ដល់កម្មករនិយោជិតដែលរងគ្រោះ ចំនួន ២០១ ៧៩៧ (ដងនាក់) សម្រាប់ការព្យាបាលនៅមន្ទីរពេទ្យ និងការថែទាំ ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ឧត្តរជីវី វិភាជន៍បូជាសព តាវកាលិកអ្នកថែទាំរក្សា និងចេញសេចក្តីសម្រេចទូទាត់ថ្លៃព្យាបាលវិជ្ជសាស្ត្រជូនមន្ទីរពេទ្យផ្លូវការ និងមន្ទីរពេទ្យក្រៅផ្លូវការ និងសេវាស្តារនីតិសម្បទា សរុបចំនួន ៧៦, ៥៦ ប៊ីលានរៀល។[38]

*តារាងទី៩. ការចំណាយប្រភេទតាវកាលិកហានិភ័យការងារ (គិតប៊ីលានរៀល)*[39]

| ការចំណាយប្រភេទតាវកាលិកហានិភ័យការងារ (គិតប៊ីលានរៀល) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ល.រ | ក. ប្រភេទតាវកាលិកហានិភ័យការងារ | ឆ្នាំ2008 | ឆ្នាំ2009 | ឆ្នាំ2010 | ឆ្នាំ2011 | ឆ្នាំ2012 | ឆ្នាំ2013 | ឆ្នាំ2014 | ឆ្នាំ2015 | ឆ្នាំ2016 | ឆ្នាំ2017 |
| ១ | តាវកាលិកព្យាបាល | - | 0.32 | 0.74 | 1.14 | 1.17 | 1.25 | 2.50 | 2.01 | 2.46 | 2.10 |
| ២ | តាវកាលិកថែទាំ | - | 0.00 | 0.02 | 0.04 | 0.03 | 0.04 | 0.07 | 0.12 | 0.17 | 0.19 |
| ៣ | តាវកាលិកបាត់បង់សមត្ថភាពបណ្តោះអាសន្ន | 0.00 | 0.13 | 0.36 | 0.57 | 0.56 | 0.77 | 1.11 | 1.92 | 2.55 | 2.39 |
| ៤ | តាវកាលិកអចិន្ត្រៃយ៍ក្រោម ២០% (*វិការ វិ*) | - | 0.01 | 0.04 | 0.05 | 0.05 | 0.14 | 0.09 | 0.18 | 0.41 | 0.53 |
| ៥ | តាវកាលិកអចិន្ត្រៃយ៍ ចាប់ពី២០% (*ធនលាភ*) | - | 0.00 | 0.01 | 0.01 | 0.06 | 0.11 | 0.16 | 0.30 | 0.47 | 0.71 |
| ៦ | វិភាជន៍បូជាសព | - | 0.02 | 0.04 | 0.08 | 0.24 | 0.39 | 0.43 | 0.75 | 0.67 | 0.84 |
| ៧ | តាវកាលិកឧត្តរជីវី (*ធនលាភ*) | - | 0.00 | 0.03 | 0.08 | 0.12 | 0.24 | 0.40 | 0.70 | 1.11 | 1.60 |
| ៨ | តាវកាលិកអ្នកចាំថែរទាំ | - | - | - | - | 0.00 | 0.00 | 0.01 | 0.03 | 0.04 | 0.06 |
| ៩ | សេវាស្តារនីតិសម្បទា (*បុរនីតិសម្បទា*) | - | - | - | - | 0.00 | 0.01 | 0.01 | 0.04 | 0.09 | 0.06 |
| | សរុប (ក) | 0.00 | 0.48 | 1.23 | 1.97 | 2.24 | 2.97 | 4.78 | 6.05 | 7.96 | 8.47 |
| ល.រ | ខ. ប្រភេទមូលដ្ឋានសុខាភិបាល | | | | | | | | | | |
| ១ | មន្ទីរពេទ្យផ្លូវការ | 0.01 | 0.59 | 1.19 | 2.12 | 2.44 | 3.27 | 4.01 | 5.01 | 6.42 | 8.31 |
| ២ | មន្ទីរពេទ្យក្រៅផ្លូវការ | - | - | - | - | 0.38 | 0.69 | 0.76 | 1.09 | 1.44 | 2.75 |
| | សរុប (ខ) | 0.01 | 0.59 | 1.19 | 2.12 | 2.82 | 3.95 | 4.77 | 6.10 | 7.86 | 11.06 |
| | សរុបរួម (ក+ខ) | 0.01 | 1.08 | 2.42 | 4.09 | 5.06 | 6.92 | 9.55 | 12.15 | 15.83 | 19.53 |
| | សរុបចំណាយ 2008-2017 | 76.64 | | | | | | | | | |

ការផ្តល់តាវកាលិកនេះ ដោយសារតែការកើនឡើងនូវគ្រោះថ្នាក់ការងារស្របគ្នានឹងការកើនឡើងកម្មករនិយោជិតដែលបានចុះបញ្ជិកា។[40]

### គ. ការវាយតម្លៃកម្រិតបាត់បង់សម្ថភាពការងារជាអចិន្ត្រៃយ៍

គណៈកម្មការវិជ្ជសាស្ត្រ បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព យុត្តិធម៌ មនសិការវិជ្ជាជីវៈ និងកសាងបានជំនឿទុកចិត្តពីសំណាក់មជ្ឈដ្ឋានទូទៅ និងសមាជិករបស់ ប.ប.ស ជាពិសេសពីនិយោជកជាម្ចាស់សហគ្រាស គ្រឹះស្ថាន មកលើការអនុវត្តរបស់ ប.ស.ស តាមរយៈការចូលរួមបង់ភាគទាន ធានារ៉ាប់រងហានិភ័យការងារជូនកម្មករនិយោជិត ហើយវាក៏បានជម្រុញ ឱ្យពួកគេ

[38] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រ៨

[39] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៩

[40] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៩

ផ្តល់ពត៌មានពិតពីចំនួនកម្មការនិយោជិត និងពីប្រាក់ខែរបស់ពួកគេ ដើម្បីជៀសវាងការបាត់បង់អត្ថប្រយោជន៍ដែលមានចែងក្នុងច្បាប់។[41]

## ២.២ ដំណើរការរបបសន្តិសុខសង្គមសម្រាប់ថែទាំសុខភាព

### ២.២.១ បញ្ជិកា និងភាគទាន

#### ក. បញ្ជិកា

ផ្អែកតាមប្រកាសលេខ ០៩៣ កប/ប្រកចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងសេចក្តីជូនដំណឹងលេខ ១២៧ កប/ស.ជ.ណា ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជិការកម្មករនិយោជិតក្នុង ប.ស.ស ក្នុងទិសដៅនេះ ប.ស.ស បានកំណត់ការអនុវត្តដោយផ្តើមចេញពីសហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងជាបន្តបន្ទាប់ឈានទៅកាន់ខេត្តដទៃទៀត ស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង។

ប.ស.ស បានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញត្រឹមឆ្នាំ២០១៧ នេះបានចំនួន ៣២៧១ សហគ្រាស មានកម្មករនិយោជិតចំនួន ១១២១៤០៩នាក់ ស្រី ៨៤៨១២៦នាក់។[42]

*តារាងទី១០. កំណត់អត្តសញ្ញាណ កម្មករនិយោជិតជាថ្មី*

| កំណត់អត្តសញ្ញាណកម្មករនិយោជិតជាថ្មី | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| បរិយាយ | សរុប | | | ថ្នាក់កណ្តាល (រាជធានីភ្នំពេញ) | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| គិតត្រឹមឆ្នាំ2017 | 3,271 | 1,121,409 | 848,126 | 1,709 | 599,080 | 451,618 | 1,562 | 522,329 | 396,508 |
| បច្ចុប្បន្នភាពសហគ្រាស និងកម្មករនិយោជិតឆ្នាំ2017 | 8,507 | 1,182,849 | 787,547 | 4,435 | 627,637 | 389,029 | 4,072 | 555,212 | 398,518 |
| ផលធៀប (%) | 38.45% | 94.81% | 107.69% | 38.53% | 95.45% | 116.09% | 38.36% | 94.08% | 99.50% |

ផ្អែកតាមតារាងទី១៥ ការធ្វើផលធៀបរវាងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញធៀបនឹងបច្ចុប្បន្នភាពសហគ្រាសចុះបញ្ជិកា សម្រេចបាន ៣៨, ៤៥ភាគរយ។[43]

[41] ប្រកាសស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ លេខ៤៤៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ប្រការ៧

[42] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១១

### ខ. ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលភាគទាន និងបង់ភាគទានមក ប.ស.ស។ អត្រាភាគទានរបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយ និងកម្មករនិយោជិតក៏ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយដែរ នៃប្រាក់ឈ្នួលមធ្យមកម្រិតលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។[44]

*តារាងទី១១. ភាគទាន គម្រោង ថែទាំសុខភាពស្ម័គ្រចិត្ត (HIP)*[45]

<table>
<tr><th colspan="9">ភាគទាន គម្រោង ថែទាំសុខភាព ដោយ ស្ម័គ្រចិត្ត (HIP)</th></tr>
<tr><td colspan="4">ឆ្នាំ2016</td><td colspan="5">0.12</td></tr>
<tr><td colspan="4">ឆ្នាំ2015</td><td colspan="5">0.61</td></tr>
<tr><td colspan="4">ឆ្នាំ2014</td><td colspan="5">0.66</td></tr>
<tr><td colspan="4">ឆ្នាំ2013</td><td colspan="5">0.11</td></tr>
<tr><td colspan="4">សរុបភាគទាន (ប៊ីលានរៀល) (ក)</td><td colspan="5">1.5</td></tr>
<tr><th colspan="9">ភាគទាន ផ្នែកថែទាំសុខភាព</th></tr>
<tr><td colspan="4">ឆ្នាំ2017</td><td colspan="5">154.75</td></tr>
<tr><td colspan="4">ឆ្នាំ2016</td><td colspan="5">17.05</td></tr>
<tr><td colspan="4">សរុបភាគទាន (ប៊ីលានរៀល) (ខ)</td><td colspan="5">171.8</td></tr>
<tr><td colspan="4">សរុបភាគទាន (ប៊ីលានរៀល) (ក) + (ខ)</td><td colspan="5">173.3</td></tr>
<tr><th colspan="9">សហគ្រាស គ្រឹះស្ថាន បានបង់ភាគទាន និងមិនបានបង់ភាគទាន</th></tr>
<tr><th rowspan="2">បរិយាយ</th><th rowspan="2">សហគ្រាសជាប់ភាគទាន (មធ្យមភាគ)</th><th rowspan="2">សហគ្រាសបានបង់ភាគទាន (មធ្យមភាគ)</th><th colspan="2">មានកម្មករនិយោជិត (មធ្យមភាគ)</th><th rowspan="2">ភាគទានសរុប (ប៊ីលានរៀល)</th><th rowspan="2">សហគ្រាសមិនបានបង់ភាគទាន (មធ្យមភាគ)</th><th colspan="2">មានកម្មករនិយោជិត (មធ្យមភាគ)</th></tr>
<tr><th>សរុប</th><th>ស្រី</th><th>សរុប</th><th>ស្រី</th></tr>
<tr><td>ឆ្នាំ2017</td><td>626</td><td>610</td><td>608,965</td><td>505,605</td><td>154.75</td><td>16</td><td>9,229</td><td>7,456</td></tr>
<tr><td>ឆ្នាំ2016</td><td>335</td><td>282</td><td>265,761</td><td>222,247</td><td>0.18</td><td>53</td><td>37,577</td><td>3,009</td></tr>
<tr><td>បម្រែបម្រួល (%)</td><td>86.94%</td><td>116.31%</td><td>129.14%</td><td>127.50%</td><td>85966.01%</td><td>-69.34%</td><td>-75.44%</td><td>147.78%</td></tr>
</table>

ក្នុងឆ្នាំ២០១៧ ប.ស.ស បានដាក់ឱ្យជាប់ភាគទានចំនួន ៦២៦ សហគ្រាស ក្នុងនោះសហគ្រាសបានបង់ភាគទាន មានចំនួន ៦១០ សហគ្រាស មានចំនួនកម្មករនិយោជិតចំនួន៦០៨៩៦៥ នាក់ ស្រី ៥០៥៦០៥នាក់។[46]

### ២.២.២ អធិការកិច្ច និងនីតិកម្ម

- ចុះទៅសម្របសម្រួល (ចុះបើកផ្លូវ)

[43] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១១

[44] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១២

[45] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១២

[46] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១២

- សហការចុះទៅពន្យល់ណែនាំពីនីតិវិធីចុះបញ្ជិកា
- សហការចុះចែកលិខិតឱ្យសហគ្រាស គ្រឹះស្ថានជាប់ភាគទាន
- សហការចុះទៅពន្យល់ណែនាំ ពីតារកាលិកថៃទាំសុខភាព និងការបង់ភាគទាន។[47]

### ២.២.៣ សេវាតាមការលិក

ដើម្បីអោយកម្មករទទួលបានសេវាដែលនៅជិតកន្លែងការងារ ឬលំនៅដ្ឋាន ក្នុងដំណាក់កាលនេះ ប.ស.ស បានពង្រីងវិសាលភាពចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានីខេត្ត គិតត្រឹមឆ្នាំ២០១៧ ចំនួន ១២៩៥ មូលដ្ឋាន រួមមានមន្ទីរពេទ្យថ្នាក់ជាតិចំនួន ០៤ មន្ទីរពេទ្យបង្អែកចំនួន ១០៧មណ្ឌលសុខភាពចំនួន ១១៦៩មូលដ្ឋាន មន្ទីរពេទ្យឯកជនចំនួន ១៥មូលដ្ឋាន។[48]

#### ក. សមាជិកទៅប្រើប្រាស់សេវា

*តារាងទី១២. សមាជិកប្រើប្រាស់ HIP[49]*

| សមាជិកប្រើប្រាស់ (HIP) | | | | |
|---|---|---|---|---|
| ឆ្នាំ2016 | ឆ្នាំ2015 | ឆ្នាំ2014 | ឆ្នាំ2013 | សរុប |
| 2,224 | 11,466 | 10,784 | 2,564 | 27,038 |
| (គិតជាមធ្យមភាគ) | | | | |
| 185 | 956 | 899 | 214 | 563.29 |

*តារាងទី១៣. ចំនួនសមាជិកទៅទទួលសេវាផ្នែក ថៃទាំសុខភាព*

| ចំនួនសមាជិកទៅទទួលសេវាផ្នែក ថៃទាំសុខភាព | | |
|---|---|---|
| បរិយាយ | នាក់ | ដងនាក់ |
| ខែវិច្ឆិកា ឆ្នាំ2016 ដល់ឆ្នាំ2017 | 218,697 | 599,647 |

47 បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៣
48 បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រ១៣
49 បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៣

### ខ. ការចំណាយតាវកាលិក

*តារាងទី១៥. ចំណាយ គម្រោងថៃទាំសុខភាពដោយស្ម័គ្រចិត្ត*[50]

| ចំណាយគម្រោង ថៃទាំសុខភាគដោយ ស្ម័គ្រចិត្ត (HIP) | |
|---|---|
| ឆ្នាំ2016 | 0.19 |
| ឆ្នាំ2015 | 0.32 |
| ឆ្នាំ2014 | 0.29 |
| ឆ្នាំ2013 | 0.04 |
| សរុបភាគទាន (ប៊ីលានរៀល ) (ក) | 0.85 |
| ចំណាយផ្នែកថៃទាំសុខភាព | |
| ឆ្នាំ2017 | 26.54 |
| ឆ្នាំ2016 | 0.01 |
| សរុបភាគទាន (ប៊ីលានរៀល ) (ខ) | 26.55 |
| សរុបភាគទាន (ប៊ីលានរៀល ) (ក) + (ខ) | 27.4 |

### ២.៣. ប្រាក់សោធន

ការរៀបចំបង្កើតឱ្យមានរបបប្រាក់សោធន សម្រាប់កម្មករនិយោជិត ក្នុងវិស័យឯកជនបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលចំពោះអនាគត នៃកម្លាំងពលកម្មសកម្ម នាពេលបច្ចុប្បន្ន និងម្យ៉ាងទៀតក៏ជាការរួមចំណែកលើកកម្ពស់ផលិតភាពពលកម្មផងដែល ព្រោះថាតាមរយៈយន្តការនេះកម្មករនិយោជិត ដែលជាកម្លាំងពលកម្មសកម្ម និងមានភាពកក់ក្តៅក្នុងចិត្តចំពោះអនាគតរបស់ខ្លួន ទោះបីជាកំពុងធ្វើការក្នុងវិស័យឯកជនក្តី ក៏ពួកគេអាចមានលទ្ធភាពរស់ដោយខ្លួនឯងបាននៅពេលជរាភាព ដោយមិនអាស្រ័យទាំងស្រុងលើ ការចិញ្ចឹមជីវិតពីកូនចៅនោះឡើយ។ ចំណុចនេះគឺជាផ្នែកមួយលើកកម្ពស់សិទ្ធិមនុស្សសម្រាប់ជនចាស់ជរា។[51]

ផ្នែកប្រាក់សោធននេះត្រូវបានថ្នាក់ដឹកនាំកំណត់ដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩ដែលបច្ចុប្បន្ន ប.ស.ស បាននិងកំពុងសិក្សាបទដ្ឋានគតិយុត្ត ដែលឈានដល់ការរៀបចំសមិទ្ធិលទ្ធភាពដាក់ឱ្យដំណើរការដោយការរំពឹងទុក និងគ្មានផលប៉ះពាល់។

[50] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី13

[51] ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២ ជំពូកទី២

# ផ្នែកទី៣៖ ការអនុវត្តជាក់ស្តែង

## ៣.១ គោលនយោបាយ និងលិខិតគតិយុត្ត

ការកើនឡើងនូវទំហំការងារចំនួនសមាជិក ស្ថានភាពនៃការរីកចម្រើនសេដ្ឋកិច្ចសង្គម និងតម្រូវការនៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋនិយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមបណ្តាលសហគ្រាស គ្រឹះស្ថាន ប.ស.ស រហូតដល់ឆ្នាំ ២០១៧ នេះ បានខិតខំប្រឹងប្រែបំពេញការងារទ្វេឡើងដោយបានរៀបចំពង្រឹង ពង្រីក និងអភិវឌ្ឍគោលនយោបាយរបបសន្តិសុខសង្គម តាមរយៈការរៀបចំផែនការរយៈពេលវែង ដែលមានលក្ខណៈស៊ីជម្រៅ និងការកសាងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ដើម្បីធានាក្នុងការផ្តល់សេវាសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាពទាន់ ពេលវេលា និងឆ្លើយតបតាមតម្រូវការ។[52]

- កិច្ចការប្រជុំរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត
  - ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំ
  - ពិនិត្យលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបាន
  - ពិនិត្យ និងអនុម័តផែនការចំណូល ចំណាយថវិកា
  - ពិនិត្យ ពិភាក្សា និងកែសម្រួលខ្លឹមសារសេចក្តីព្រាងប្រកាស ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត
  - ពិនិត្យ ពិភាក្សា និងកែសម្រួលខ្លឹមសារសេចក្តីព្រាងប្រកាស ស្តីពីការកំណត់អត្រាភាគទាន បែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផែនថែទាំសុខភាព។[53]

## ៣.២ ការគ្រប់គ្រង និងការបណ្តុះបណ្តាលធនធានមនុស្ស

### ៣.២.១ ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

#### ក. កាងាររដ្ឋបាល

ការងាររដ្ឋបាល មានតួនាទីយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងឯកសារ ការផ្គត់ផ្គង់ និងការគ្រប់គ្រងមន្ត្រីបុគ្គលិកដើម្បីធានាបាននូវការអនុវត្តបទបញ្ជាផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព និងស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។ នៅឆ្នាំ២០១៧នេះរដ្ឋបាលរបស់ ប.ស.ស សម្រេចបាន៖[54]

[52] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រ១៥
[53] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៥
[54] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៦

➢ ផ្នែកគ្រប់គ្រងលិខិត
- គ្រប់គ្រងលិខិតចូល
- គ្រប់គ្រងលិខិតចេញ

➢ ការងារកសាងលិខិត[55]
- រៀបចំទូទាត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ជូនមន្ត្រី និងបុគ្គលិក
- រៀបចំបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដល់បុគ្គលិក
- រៀបចំតម្លើងកម្រិតមុខងារ និងប្រាក់កម្រៃលើកទឹកចិត្ត ជូនមន្ត្រីរាជការ
- រៀបចំតម្លើងឋានន្តរស័ក្ក ថ្នាក់តាមវេន និងតាមសញ្ញាបត្រ រួមទាំងប្រាក់កម្រៃលើកទឹកចិត្ត ជូនមន្ត្រីរាជការប្រចាំ ប.ស.ស
- រៀបចំតម្លើងឋានន្តរស័ក្ក ថ្នាក់តាមវេន និងប្រាក់កម្រៃលើកទឹកចិត្ត រួមទាំងរំលឹកប្រាក់កម្រៃលើកទឹកចិត្តជូនមន្ត្រីរាជការ ប.ស.ស
- រៀបចំវាយតម្លៃមន្ត្រីរាជការ ស្នើសុំគ្រឿងឥស្សរយស ប្រចាំ ប.ស.ស
- រៀបចំគោលការណ៍ស្នើសុំ ប្រជុំពិភាក្សាលើការកំណត់ចំនួនជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាប្រចាំ ប.ស.ស
- កែសម្រួល និងផ្តល់ប្រាក់កម្រិតមុខងារ ជូនមន្ត្រីរាជការ ដែលបានទទួលការតែងតាំងពីបេឡាជាតិរបបសន្តិសុខសង្គម
- រៀបចំឯកសារបញ្ចូលបុគ្គលិកសាកល្បងការងារ
- បានដាក់បញ្ចូលបុគ្គលិកឱ្យពេញសិទ្ធិ។

### ខ.ការងារហិរញ្ញវត្ថុ

ការងារគណនេយ្យ និងកិច្ចការហិរញ្ញវត្ថុរបស់ ប.ស.ស ប្រតិបត្តិការតាមរយៈប្រព័ន្ធធានាគារទាំងស្រុងពោលគឺរាល់កិច្ចដំណើរការនៃការគ្រប់គ្រងចំណូល និងចំណាយមានជាអាទិ៍ ការប្រមូលភាគទានពីសហគ្រាស គ្រឹះស្ថាន ការបង់ប្រាក់ពិន័យ ការចំណាយតាវកាលិកដល់កម្មករនិយោជិតដែលរងហានិភ័យការងារ និងការចំណាយរដ្ឋបាល ត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់តាមប្រព័ន្ធធានាគារក្នុងនោះមាន ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារឯកទេសរីង ក្នុងការ

[55] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៦

ប្រមូលភាគទាន បើកផ្តល់តាវកាលិក និងការរក្សាមូលនិធិបម្រុងសន្តិសុខសង្គម ក្នុងគោលដៅធានាពីប្រសិទ្ធភាព និងគណនេយ្យភាព។ ក្នុងដំណើរការនៃកិច្ចប្រតិបត្តិការ ប.ស.ស បានអនុវត្តការងារសំខាន់ៗ មួយចំនួនដូចខាងក្រោម៖[56]

- រៀបចំផែនការចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ (លើទិសដៅអនុវត្ត)
- រៀបចំរបាយការណ៍ចំណូល និងចំណាយសាច់ប្រាក់លម្អិតប្រចាំខែក្នុងឆ្នាំ២០១៧
- កត់ត្រាចំណូលភាគទានប្រចាំខែ ដែលបានមកពីការប្រមូលភាគទានតាមរោងចក្រសហគ្រាសនីមួយៗនៅក្នុង Account Receivable
- កត់ត្រាចំណាយប្រចាំថ្ងៃនៅក្នុង Journal Entry
- កត់ត្រាចំណាយជំពាក់ជាសាច់ប្រាក់ប្រចាំខែ សម្រាប់អង្គភាពផ្គត់ផ្គង់ដូចជាថ្លៃព្យាបាលនៅក្នុងតាមមន្ទីរពេទ្យនីមួយ និងតាវកាលិកធនលាភដែលសមាជិក ប.ស.ស ទទួលបានក្នុង Account Payable
- រៀបចំអត្រាប្តូរប្រាក់សម្រាប់ភាគទានប្រចាំខែនីមួយៗ
- ពិនិត្យចំណាយផ្សេងៗដូចជា ចំណាយបេសកកម្ម ចំណាយរដ្ឋបាល ចំណាយបង្ការហានិភ័យការងារ និងចំណាយតាវកាលិក
- រៀបចំបង់ពន្ធលើប្រាក់លើកទឹកចិត្តប្រចាំខែនីមួយៗ
- រៀបចំបញ្ជីបើកប្រាក់បៀវត្សប្រចាំខែនីមួយៗ
- ផ្ទៀងផ្ទាត់របាយការណ៍ធនាគារជាមួយសៀវភៅបេឡា។

### ៣.២.២ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស

កិច្ចសហប្រតិបត្តិការ និងការបណ្តុះបណ្តាលធនធានមនុស្ស ជាការងារមួយសំខាន់នៅក្នុងការអភិវឌ្ឍន៍អង្គភាព និងពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងផ្នែកដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីធានានូវនិរន្តរភាពនៃកិច្ចដំណើរការរបស់អង្គភាពលើការរៀបចំផែនការ បែបបទ និងនីតិវិធីការងារ ក៏ដូចជាការអភិវឌ្ឍន៍នូវចំនេះដឹងការដកស្រង់និងការផ្លាស់ប្តូរបទពិសោធន៍ការងារថ្មីៗ។ កិច្ចសហប្រតិបត្តិការ និងការងារបណ្តុះបណ្តាលធនធានមនុស្ស ក៏ជាការចូលរួមចំណែកនៅក្នុងសកម្មភាពការងារសង្គមទាំងមូលឱ្យមានភាពរីកចម្រើនផង

[56] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៧

ដែរ ដែលថ្នាក់ដឹងនាំក៏ដូចជាមន្ត្រី ប.ស.ស បានចូលរួមកិច្ចប្រជុំពិភាក្សាផ្តល់យោបល់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងនៅក្នុងប្រទេស និងក្រៅប្រទេសដូចខាងក្រោមនេះ៖[57]

**ក.ការងារបណ្តុះបណ្តាលធនធានមនុស្ស**

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធី និងដំណើរការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពី នីតិវិធីនៃការចុះបញ្ជិកា កម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពដល់មន្ត្រី និងបុគ្គលិក ប.ស.ស តាមសាខា ខេត្ត/ខណ្ឌ
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពី Administration of old age person ដល់មន្ត្រីថ្នាក់ដឹកនាំ និងថ្នាក់ការិយាល័យនៃ ប.ស.ស
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីនីតិវិធីនៃការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព អនុគណនី ៦១១២ អនុកម្មវិធីទី ៤ ដល់មន្ត្រី និងបុគ្គលិក
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុង ស្តីពីបច្ចុប្បន្នភាពការងារជំនាញ ទាក់ទង នឹងរបបសន្តិសុខសង្គម តាមបណ្តាលសាខាខេត្ត-ខណ្ឌ ដល់មន្ត្រី និងបុគ្គលិក
- រៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីនីតិវិធីនៃការចុះបញ្ជិកា សហគ្រាស គ្រឹះស្ថានដល់បុគ្គលិកទើបតែចូលថ្មី។

**ខ. ការងារក្នុងប្រទេស**

កិច្ចសហប្រតិបត្តិការ និងបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស ប.ស.ស បានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាល និងធ្វើបច្ចុប្បន្នភាពការងារផ្ទៃក្នុងដល់មន្ត្រី និងបុគ្គលិកជាប្រចាំរៀងរាល់ឆ្នាំ។ ថ្នាក់ដឹកនាំមន្ត្រី និងបុគ្គលិកនៃ ប.ស.ស បានរៀបចំ និងចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពិភាក្សាការងារ ការរៀបចំផែនការអភិវឌ្ឍ និងសិក្ខាសាលាបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹងតាមបណ្តាក្រសួង និងអង្គការ និងស្ថាប័នពាក់ព័ន្ធនានាទូទាំងប្រទេសជាច្រើនលើក នៅក្នុងឆ្នាំ ២០១៧ រួមមាន ៖[58]

---

[57] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៧

[58] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី១៨

- ចូលរួមសិក្ខាសាលាលើកម្ពស់ការយល់ដឹងអំពីបទប្បញ្ញត្តិ និងប្រកាសទាក់ទងនឹងលក្ខខណ្ឌការងារសម្រាប់កម្មករការងារតាមផ្ទះ នៅសណ្ឋាគារ Himawari
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោ-បាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលនៃការវិភាគទិន្នន័យ ស្តីពីបទពិសោធន៍ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សាផ្សេងៗនៅសណ្ឋាគារទ្បែនស្កុប
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី០២ លើសេចក្តីព្រាងបឋមច្បាប់ស្តីពីការការពារសាក្សី និងច្បាប់ស្តីពី ការពារបុគ្គលរាយការណ៍ នៅអង្គភាពប្រឆាំងអំពើពុករលួយ
- ចូលរួមប្រជុំពិភាក្សាពាក់ព័ន្ធ នឹងការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅអនុវត្តឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស គ្រឹះស្ថាន នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី សិទ្ធិរបស់យុវជននៅកន្លែងការងារ នៅទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ចូលរួមសិក្ខាសាលាស្តីពី ការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសា-ធារណៈនៅសណ្ឋាគារសុខាភ្នំពេញ
- ចូលរួមប្រជុំពិនិត្យវាយតម្លៃដំឡើងឋានន្តរស័ក្តិ និងថ្នាក់ សម្រាប់ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាស្តីពី ការបញ្ជ្របការយល់ដឹងពីប្រព័ន្ធ FMIS នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមសិក្ខាសាលាស្តីពីការពិនិត្យមើលឡើងវិញនូវលទ្ធផលប្រចាំឆ្នាំនៅសណ្ឋាគារភ្នំពេញ

- ចូលរួមសិក្ខាសាលាស្តីពី ការវាយតម្លៃហានិភ័យ( Actuarial Study ) សម្រាប់ប្រព័ន្ធសោធននៅកម្ពុជា នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលាស្តីពីដំណើរការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងាររយ:ពេល០៣ឆ្នាំ(២០១៧-២០១៩) នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលាត្រីភាគី ពិនិត្យប្រចាំឆ្នាំស្តីពី កម្មវិធីការងារសមរម្យសម្រាប់កម្ពុជា (២០១៦-២០១៨) នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី វិទ្យាសាស្ត្រសេដ្ឋកិច្ចសម្រាប់អ្នកដែលមិនមែនជាអ្នកសេដ្ឋកិច្ច នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពដំណាក់កាលទី ០៣ នៅសណ្ឋាគារ OC Boutique ខេត្តព្រះសីហនុ
- ចូលរួមវគ្គបណ្តុះបណ្តាលពិសេស នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមកិច្ចប្រជុំអនុគណ:កម្មការទីមួយស្តីពីការបង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌ នៅស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមកិច្ចប្រជុំស្តីពី កម្មវិធីបណ្តុះបណ្តាលកម្មសិក្សាបច្ចេកទេសជាមួយភាគីជប៉ុននៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី លទ្ធផលនៃការសិក្សាពីលទ្ធភាពគ្របដណ្តប់ក្រុមប្រជាជនសម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅសណ្ឋាគារភ្នំពេញ
- ចូលរួមសិក្ខាសាលា ពិគ្រោះយោបល់ស្តីពី ចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី
- ចូលរួមសិក្ខាសាលាស្តីពី ត្រីភាគីត្រៀមថ្នាក់ជាតិ នៅសណ្ឋាគារ Angkor Paradise
- ចូលរួមសិក្ខាសាលាស្តីពី បច្ចុប្បន្នភាពនៃគោលបំណង និងគោលដៅសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅសណ្ឋាគារ កាំបូឌីយ៉ាណា

- ចូលរួមសិក្ខាសាលាត្រីភាគីស្តីពី ពិនិត្យប្រចាំឆ្នាំ ស្តីពីកម្មវិធីការងារសមរម្យសម្រាប់កម្ពុជា នៅសណ្ឋាគារភ្នំពេញ។

**គ .ការងារក្រៅប្រទេស**

ក្រៅពីការងារលើកកម្ពស់ធនធានមនុស្ស និងកិច្ចសហប្រតិបត្តិការក្នុងប្រទេស ការទំនាក់ទំនងក្រៅប្រទេសជាការងារមួយដ៏សំខាន់ នៅក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍបរទេសនានា និងការធ្វើសមាហរណកម្មវិស័យសន្តិសុខសង្គមរបស់កម្ពុជាទៅតំបន់ ដើម្បីឱ្យមានការផ្លាស់ប្តូរនូវបទពិសោធន៍ បច្ចេកទេសការងារថ្មីៗ យកមកធ្វើការអភិវឌ្ឍន៍នៅក្នុងប្រទេស។ ឆ្នាំ២០១៧ នេះ ប.ស.ស បានបំពេញនូវការងារក្រៅប្រទេសសំខាន់ៗ មួយចំនួនសម្រាប់វិស័យសន្តិសុខសង្គម ដូចខាងក្រោមៈ[59]

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលប្រាក់ឈ្នួល នៅសាធារណៈរដ្ឋកូរ៉េ
- សោធនជរាភាព នៅប្រទេសវៀតណាម
- ចូលរួមសិក្ខាសាលាស្តីពី ប្រសិទ្ធភាពនៃកម្មវិធីសន្តិសុខសង្គម នៅក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី នៅប្រទេសឥណ្ឌូណេស៊ី
- ចូលរួមសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំសម្រាប់ការគ្របដណ្តប់របបថៃទាំសុខភាពជាសកល នៅប្រទេសជប៉ុន
- ចូលរួមទស្សនកិច្ចស្តីពី ប្រព័ន្ធផ្តល់ពត៌មានតាមទូរស័ព្ទ (Call center) នៅ SSO ប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការធានារ៉ាប់រងសុខភាពសង្គម នៅសាធារណៈរដ្ឋកូរ៉េ
- ចូលរួមសិក្ខាសាលាស្តីពី ការទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ ដើម្បីឈានទៅការគ្របដណ្តប់សេវាសុខាភិបាលជាសកល នៅប្រទេសហ្គាណា
- ចូលរួមសន្និសិទ្ធសន្តិសុខសង្គមអន្តរជាតិស្តីពីអនាគតនៃការងារ នៅប្រទេសម៉ាឡេស៊ី
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៤នៅប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីការរៀបចំប្រព័ន្ធសោធននិវត្តន៍នៅប្រទេសអាឡឺម៉ង់
- ចូលរួមសន្និសិទជាន់ខ្ពស់អាស៊ានស្តីពីកិច្ចគាំពារសង្គម នៅប្រទេសហ្វីលីពីន

[59] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២០

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសេវាស្តារនីតិសម្បទាសម្រាប់កម្មករពិការកាយសម្បទានៅប្រទេសថៃ
- ចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីស្តីពី ការរៀបចំប្រព័ន្ធធានារ៉ាប់រងសុខភាពនៅប្រទេសអាឡឺម៉ង់
- ចូលរួមសិក្ខាសាលាស្តីពីយន្តការហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពសម្រាប់ធានារ៉ាប់រងសង្គម និងនិរន្តភាពនៃប្រព័ន្ធសោធនក្នុងអាស៊ាន នៅប្រទេសវៀតណាម
- ចូលរួមសិក្ខាសាលាអន្តរជាតិស្តីពិការពង្រីកការគ្របដណ្តប់សន្តិសុខសង្គមក្នុងសម័យកាល ដែលមានសេដ្ឋកិច្ចជួបប្រទះបញ្ហានៅប្រទេសឥណ្ឌូណេស៊ី
- ចូលរួមកិច្ចប្រជុំកម្មវិធី អាទិភាពជាសកលរបស់អង្គការ ILO ស្តីពីការបង្កើតមូលដ្ឋានគាំពារសង្គមសម្រាប់ទាំងអស់គ្នា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស
- ចូលរួមកិច្ចប្រជុំពិភាក្សាលើកិច្ចប្រជុំពិភាក្សាលើកិច្ចព្រមព្រៀងស្តីពីតាវកាលិកជរាភាពនៅទីក្រុងបាងកក ប្រទេសថៃ
- ចូលរួមកិច្ចប្រជុំវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាពាក់ព័ន្ធនឹងដំណើរការនៃមុខងាររបស់អង្គភាពត្រួតពិនិត្យ និងវាយតម្លៃកម្រោងធានារ៉ាប់រងសុខភាពនៅទីក្រុងសេអ៊ូល សាធារណៈរដ្ឋកូរ៉េ។

## ៣.៣. ការផ្សព្វផ្សាយ និងការបង្ការហានិភ័យការងារ

### ៣.៣.១ ក្រុមការងារ ទ.ស.ប.ក

ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ ( ទ.ស.ប.ក) មានតួនាទីសិក្សាស្រាវជ្រាវ រកមូលហេតុករណីសន្លប់របស់កម្មករនិយោជិតចាត់វិធានាការសង្រ្គោះបន្ទាន់ និងសម្របសម្រួលជាមួយមន្ទីរពេទ្យ ជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីឱ្យជនរងគ្រោះទទួលបានការ សង្គ្រោះបន្ទាន់ និងចូលរួមរៀបចាំការផ្សព្វផ្សាយពីកម្មវិធីបង្ការគ្រោះថ្នាក់ការងារ។ ក្រុមការងារ ទ.ស.ប.ក បាននឹងកំពុងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំដូចភ្លៀងរលឹម ដើម្បីឱ្យនិយោជក តំណាងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ទទួលបានការអប់រំ ស្តីពីលក្ខខណ្ឌការងារ លក្ខខណ្ឌ អនាម័យ និងសុវត្ថិភាពការងារ ការទប់ស្កាត់ករណីកម្មករនិយោជិតសន្លប់ បង្ការគ្រោះថ្នាក់ចរាចរណ៍ ដោយមធ្យោបាយធ្វើដំណើរកម្មករនិយោជិត និងអត្ថប្រយោជន៍របបសន្តិសុខសង្គមក្នុងន័យទប់ស្កាត់ និងបង្ការគ្រោះថ្នាក់ការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ឱ្យស្ថិតនៅកម្រិតទាបបំផុត។[60]

[60] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២៥

ក្នុងបាតុភាពករណីកម្មករនិយោជិតសន្លប់ ក្រុមការងារ ទ.ស.ប.ក ក៏បានចុះជួយសម្រប់សម្រួលចាត់វិធានការកែលំអ និងជួយសង្រោះ។[61]

*តារាងទី១៥. ការប្រជុំផ្សព្វផ្សាយ អប់រំទប់ស្កាត់ករណីកម្មករសន្លប់ [62]*

| ការប្រជុំផ្សព្វផ្សាយ អប់រំទប់ស្កាត់ករណីកម្មករសន្លប់ | | | | |
|---|---|---|---|---|
| បរិយាយ | សហគ្រាស | | កម្មករនិយោជិត | |
| | រោងចក្រ | លើក | សរុប | ស្រី |
| ឆ្នាំ2017 | 88 | 88 | 7,296 | 5,129 |
| ឆ្នាំ2016 | 77 | 77 | 13,042 | 11,738 |
| ឆ្នាំ2015 | 90 | 90 | 13,450 | 12,105 |
| ឆ្នាំ2014 | 27 | 19 | 3,100 | 2,790 |
| ឆ្នាំ2013 | 71 | 32 | 10,917 | 9,825 |
| ឆ្នាំ2012 | 15 | 105 | 28,000 | 25,200 |
| សរុប 2012-2017 | 368 | 411 | 75,805 | 66,787 |

### ៣.៣.២ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត[63]

បច្ចុប្បន្នគ្រោះថ្នាក់ចរាចរណ៍ ជាបន្ទុកដ៏ធំដល់រាជរដ្ឋាភិបាល ដោយសារជនរងគ្រោះបានបាត់បង់ជីវិត របួស ពិការ ខូតខាតទ្រព្យសម្បត្តិរដ្ឋ និងឯកជនយ៉ាងច្រើនជាពិសេសកម្មករកម្មការិនី ដែលទទួលរងគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងធ្វើដំណើរទៅ និងត្រឡប់មកពីបំពេញការងារដោយមធ្យោបាយនានា។ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយ ក៏ដូចជាទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ នេះបេឡាជាតិរបបសន្តិសុខសង្គមតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតហៅកាត់ថា (ប.ផ.ក) ដោយសេចក្តីសម្រេចលេខ ០០២/១៣ ប.ក/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៣ ដែលមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ តំណាងភាគីនិយោជក កម្មករនិយោជិត និងអង្គការជនពិការអន្តរជាតិ(HI)។ ក្រុមការងារនេះមានភារកិច្ចកសាងផែនការសកម្មភាព សិក្សាស្រាវជ្រាវប្រមូលទិន្នន័យវិភាគ ស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ផ្សព្វផ្សាយអប់រំណែនាំពីច្បាប់ និងសុវត្ថិភាពចរាចរណ៍ និងសហការជាមួយអាជ្ញាធរដែនដី សមត្ថកិច្ចពាក់ព័ន្ធក្នុងការចាត់

[61] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ, លេខទំព័រទី២៧

[62] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២៦

[63] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២៧

វិធានការបង្ការ និងទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ ព្រមទាំងអនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់មន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្រាប់ឆ្នាំ២០១៧ នេះ ក្រុមការងារបានរៀបចំផែនការការងារ និងសម្ភារឧបទ្ទេសសម្រាប់ផ្សព្វផ្សាយអប់រំដល់អ្នកបើកបរដឹកកម្មករនិយោជិត កម្មករ/ កម្មការិនី ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក បច្ចេកទេសត្រួតពិនិត្យយានយន្ត វិជ្ជាសង្គ្រោះបឋម ពាក់មួកសុវត្ថិភាព និងវិធីការពារគ្រោះថ្នាក់ផ្សេងៗជាពិសេសចំណុចដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ជាញឹកញាប់ និងការងារមួយចំនួនទៀត បានគូរឱ្យកត់សម្គាល់ ដូចបង្ហាញលទ្ធផលខាងក្រោមៈ

*តារាងទី១៦. ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត*[64]

| ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គ្រោះថ្នាក់ចរាចរណ៍របស់កម្មករ | ករណី | ស្ថានភាពជនរងគ្រោះ (នាក់) | | | | | យានយន្តទូទៅ (%) | | | យានយន្តបង្កហេតុ (%) | | តាមវិស័យ (%) | | |
| | | ស្លាប់ | ធ្ងន់ | ស្រាល | សរុប | ស្រី | ម៉ូតូ | រថយន្ត | ផ្សេងៗ | បង្កឡើដោយយានយន្តដឹកកម្មករ | បង្កឡើងដោយយានយន្ត | | | |
| ឆ្នាំ2017 | 1,771 | 36 | 320 | 1,970 | 2,326 | 2,326 | 87.62% | 3.96% | 8.42% | 45.10% | 54.52% | 50.52% | 18.71% | 30.77% |
| ឆ្នាំ2016 | 7,592 | 118 | 1,293 | 7,898 | 9,309 | 5,839 | 73.00% | 15.00% | 13.00% | 39.00% | 61.00% | 66.00% | 7.00% | 27.00% |
| បម្រែបម្រួល ( %) | -76.67% | -69.49% | -75.25% | -75.06% | -75.01% | -60.16% | 20.03% | -73.60% | -35.23% | 15.64% | -10.62% | -23.45% | 167.29% | 13.96% |

## ការងារផ្សព្វផ្សាយដល់កម្មករនិយោជិត

*តារាងទី១៧. ផ្សព្វផ្សាយច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក និងវិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍*[65]

| ផ្សព្វផ្សាយច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក និងវិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ | | | | | | |
|---|---|---|---|---|---|---|
| បរិយាយ | សហគ្រាស | | កម្មករនិយោជិត | | | |
| | រោងចក្រ | លើក | កម្មករនិយោជិត | អ្នកបើកបរ | សរុបរួម | ស្រី |
| ឆ្នាំ2017 | 671 | 682 | 60,677 | 30,241 | 90,918 | 55,093 |
| ឆ្នាំ2016 | 154 | 137 | 24,922 | 1,488 | 26,410 | 15,794 |
| ឆ្នាំ2015 | 307 | 103 | 17,776 | 3,591 | 21,367 | 12,820 |
| ឆ្នាំ2014 | 123 | 22 | 2,675 | 1,600 | 4,275 | 2,565 |
| ឆ្នាំ2013 | 172 | 24 | 2,880 | 1,867 | 4,747 | 2,848 |
| សរុប | 1,427 | 968 | 108,930 | 38,787 | 147,717 | 89,120 |

[64] បេឡាជាតិរបបសន្តិសុខសង្គម, (២០០៨-២០១៧),របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ, លេខទំព័រទី២៧

[65] បេឡាជាតិរបបសន្តិសុខសង្គម, (២០០៨-២០១៧),របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ, លេខទំព័រទី២៧

# ជំពូកទី២

# ការអនុវត្តសំណងគ្រោះថ្នាក់ការងារ

## ផ្នែកទី១៖ លទ្ធិផលសំណងឆ្នាំ២០០៨-២០១៧

លទ្ធផលសំណងរបស់បេឡាជាតិរបបសន្តិសុខសង្គមមានដូចខាងក្រោម៖[66]

- **សេវាកែលម្អសម្បទា៖** មានជាអាទិ៍ បង្វឹកបង្ហាត់ធ្វើយ៉ាងណាឱ្យជនរងគ្រោះអាចរស់នៅប្រកបការងារ និងជីវភាពសង្គមបាន ដោយការព្យាបាលតាមរយៈការធ្វើចលនា ការផ្តល់អវៈយវៈសិប្បនិមិត្ត និងការសម្រួលធ្វើចលនានានាដូចជារទេះរុញ ឬរទេះស្វ័យប្រវត្តិដែលអាចឱ្យជនរងគ្រោះបម្លាស់ទីពីកន្លែងមួយទៅកន្លែងមួយបាន។ បង្វិកជនរងគ្រោះឱ្យចេះប្រើសម្ភារ ឬអវៈយវៈសិប្បនិមិត្តសម្រាប់ការងារប្រចាំថ្ងៃ និងទំនាក់ទំនងសង្គម។
- **បណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើយ៉ាងណាអោយជនរងគ្រោះអាចត្រឡប់ធ្វើការងារវិញបាននៅកន្លែងដដែល ឬនៅកន្លែងផ្សេងស្របទៅតាមសម្បទា ដែលយើងបានបណ្តុះបណ្តាល។ករណីខ្លះទៀតត្រូវបណ្តុះបណ្តាលជំនាញថ្មី ដើម្បីឱ្យជនរងគ្រោះបានប្រកបរបរចិញ្ចឹមជីវិតស្របទៅតាមពិការភាពរបស់ខ្លួន ហើយនឹងតម្រូវការជាក់ស្តែងនៅក្នុងសង្គម
- **ការស្វែងរកទីផ្សារការងារជូនជនរងគ្រោះ៖**នៅពេលដែលជនរងគ្រោះត្រូវបានបណ្តុះបណ្តាលហើយ យើងត្រូវរកទីផ្សារជូនគាត់ដើម្បីឱ្យមានលទ្ធភាពរកចំណូលឡើងវិញ តាមអ្វីដែលនយោបាយរបស់រដ្ឋមាន។ ការងារនេះទាមទារឱ្យមានកាតព្វកិច្ចរបស់និយោជក ជ្រើសរើសជនពិការចូលធ្វើការ ដែលមានចែងក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

កម្មករនិយោជិត ដែលទទួលរង ហានិភ័យការងារបណ្តាលឱ្យ បាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈ សប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយ ប.ស.ស។ កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាព ការងារអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវឡើងវិញ ស្របតាមលក្ខខណ្ឌ ដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[66] http://www.nssf.gov.kh/default/ ចូលមើលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨

### ១.១ ការទទួលគ្រោះថ្នាក់រហូតដល់ស្លាប់

ក្នុងករណីដែលទទួលរងហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍បូជាសព ដែលមានចំនួន ៤.០០០.០០០ (បួនលាន)រៀល។ ប្រាក់វិភាជន៍នេះត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។ លើសពីនេះទៀត មានការផ្តល់សេវាដឹកសពដល់គេហដ្ឋាន។[67]

### ១.២ ឧត្តរជីវី

#### ១.២.១ លក្ខខណ្ឌដែលត្រូវទទួលបាន តាវកាលិកឧត្តរជីវី សិទ្ធិវ័ន្តរបស់សមាជិកនៃ ប.ស.ស

ល័ក្ខខ័ណ្ឌដែលត្រូវទទួលបាន តាវកាលិកឧត្តរជីវី សិទ្ធិវន្តរបស់សមាជិកនៃ ប.ស.ស ត្រូវបានកំណត់ខាងក្រោម៖[68]

- ប្តី ឬ ប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ដោយបានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមាន គ្រោះថ្នាក់ការងារ ឬ មុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងាររវាង ប្តី ឬ ប្រពន្ធ ដែលជាសមាជិកនៃ ប.ស.ស។
- កូនដែលមានអាយុត្រឹម ១៨( ដប់ប្រាំបី) ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាព ដូចខាងក្រោម៖
  - កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬ ករណីមរណភាព នៃ ប្តី ឬ ប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយ ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ។
  - កូនចិញ្ចឹមរបស់សមាជិកនៃ ប.ស.ស។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិធរមាន។
  - អាយុកូននៅក្នុងបន្ទប់អាចកំណត់ដល់ ២១ឆ្នាំ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនកំពុងរៀននៅគ្រឹះស្ថាន សិក្សាសាធារណៈ ឬឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិត

[67] ប្រកាសស្តីពីការកែសម្រួល ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ លេខ២៣៣ ក.ប/ប្រក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ប្រការ១០ថ្មី

[68] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម លេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០០៧ មាត្រា៣៤

បញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬមានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារមានប្រាក់ឈ្នួល។

- ឪពុកម្តាយឬមនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកនៃប.ស.ស
- សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយពៅពេលដែលសាមីជនទទួលមរណភាព ឬរៀបអាពាហ៍ពិពាហ៍ថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមក ប.ស.ស យ៉ាងយូរ ៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបាជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

### ១.២.២ តាវកាលិកឧត្តរជីវី

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ តាមអត្រាដូចខាងក្រោម៖[69]

**ករណីសិទ្ធិវន្តមានរួមទាំងប្រពន្ធ ឬ ប្តី កូន និងឪពុកម្តាយ ឬ មនុស្សចាស់ជរានៅក្នុងបន្ទុក**

- ប្រពន្ធ ឬ ប្តី =៣/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក= ២/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក= ៧% បឈម

**ករណេសិទ្ធិវន្ត មានតែប្រពន្ធ ឬ ប្តី និង/ ឬ កូន**

- ប្រពន្ធ ឬ ប្តី= ៣/៥ x ៧០% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x៧០% បឈម

**ករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬ មនុស្សចាស់ជរា**

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

**ករណីសិទ្ធិវន្តមានតែកូន និង ឪពុកម្តាយ ឬ មនុស្សចាស់ជរា**

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

**ករណី សិទ្ធិវន្តមានតែប្រពន្ធ ឬ ប្តី និងឪពុកម្តាយ ឬ មនុស្សចាស់ជរា**

[69] ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ លេខ១០៩ក.ប/ប្រ. ចុះថ្ងៃទី១៦ខែមិថុនាឆ្នាំ២០០៨ ប្រការ១១

- ប្រពន្ធ ឬប្ដី = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬ មនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

## ផ្នែកទី២៖ បញ្ហាប្រឈម

### ២.១. បញ្ហាប្រឈមការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ

#### ២.១.១ បញ្ហាប្រឈមលើការពង្រីក និងពង្រីកការអនុវត្តហានិភ័យការងារ

បេឡាជាតិរបបសន្តិសុខសង្គម នៅជួបបញ្ហាប្រឈមមួយចំនួនដូចតទៅ៖[70]

**ក. និយោជកសហគ្រាស គ្រឹះស្ថាន មួយចំនួនតូច ៖**

- មិនទាន់ស្គាល់ពី ប.ស.ស ច្បាស់ពាក់ព័ន្ធនឹងនីតិវិធីចុះបញ្ជិកា បង់ភាគទាន និងផ្ដល់ទិន្នន័យកម្មករនិយោជិតមិនច្បាស់តាមខែនីមួយៗ
- ពិបាកជួបម្ចាស់សហគ្រាស (ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ...)
- ពន្យាពេលក្នុងការចុះកំណត់អត្តសញ្ញាណកម្មករនិយោជិត
- បិទទ្វារ ផ្អាកសកម្មភាព ប្ដូរអាសយដ្ឋាន ប្ដូររដ្ឋបាលថ្មី ប្ដូរម្ចាស់ ប្ដូរឈ្មោះថ្មី ដោយមិនបានជូនដំណឹងមក ប.ស.ស
- ប្រភេទសិប្បកម្មមិនរៀបរយ គ្មានឯកសារគតិយុត្តត្រឹមត្រូវ
- ផ្ដល់របាយការណ៍ហានិភ័យការងារមិនត្រឹមត្រូវ យឺតយ៉ាវ រក្សាទុកឯកសារទាមទារតាវកាលិកយូរ ឬចាំសរុបរួមទើបផ្ញើមក ប.ស.ស
- មិនទាន់បង់ភាគទានហានិភ័យការងារ

**ខ. កម្មករនិយោជិតមួយចំនួនតូច៖**

- មិនទាន់យល់ច្បាស់ពី ប.ស.ស មិនទាន់មានឯកសារបញ្ជាក់ពីអត្តសញ្ញាណច្បាស់ និងទាមទារតាវកាលិកមិនមែនគ្រោះថ្នាក់ការងារ
- មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍
- ទៅទទួលការព្យាបាលនៅមន្ទីរពេទ្យ ដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស និង ប្រើប្រាស់សេវាមិនចំគោលដៅ

[70] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី២៨

**គ. សេវាមូលដ្ឋានសុខាភិបាលមួយចំនួន៖**

- គុណភាពនៃការផ្តល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ របស់មន្ទីរពេទ្យមូលដ្ឋានមួយចំនួននៅមានកម្រិត។

### ២.១.២ បញ្ហាប្រឈមលើការពង្រីក និងពង្រីកការអនុវត្តផ្នែកថែទាំសុខភាព

ការអនុវត្តផ្នែកថែទាំសុខភាព បេឡាជាតិរបបសន្តិសុខសង្គមជួបបញ្ហាប្រឈមមួយចំនួនដូចតទៅ៖[71]

**ក. និយោជកសហគ្រាស គ្រឹះស្ថានមួយចំនួនតូច៖**

- ❖ ការកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ
  - ✓ ពន្យាពេលក្នុងការចុះ
  - ✓ ខ្លាចប៉ះពាល់សង្វាក់ផលិតកម្ម ដោយបញ្ជូនកម្មករមកតិច
- ❖ មិនបានរាយការណ៍ពីចំនួនបុគ្គលិកចូលថ្មី និងលាឈប់ពីការងារ និងមួយចំនួនទៀតបានរាយការណ៍ដែរ តែមិនច្បាស់លាស់
- ❖ មិនទាន់បង់ភាគទានផ្នែកថែទាំសុខភាព។

**ខ. កម្មករនិយោជិតមួយចំនួនតូច៖**

- ❖ ការកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ
  - ✓ ខ្ជិលយកសារគេប្រើ មិនហ៊ានប្រាប់ខ្លាចគេបញ្ឈប់ពីការងារ
  - ✓ មិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ផ្នែកថែទាំសុខភាព
  - ✓ ខ្លាចបាត់បង់អតីតភាពការងារពេលប្តូរឈ្មោះត្រឹមត្រូវវិញ
- ❖ ព្យាយាមលាក់បាំងមិនព្រមបង្ហាញកាតដោយយល់ថា គ្រូពេទ្យផ្តល់សេវាល្អទាល់តែបង់ប្រាក់ភ្លាមៗ។

**គ. សេវាមូលដ្ឋានសុខាភិបាលមួយចំនួនតូច៖**

គ្រូពេទ្យមួយចំនួនតូចមិនទាន់យល់ច្បាស់អំពីលំហូរនៃការផ្តល់សេវាជូនសមាជិកដោយរលូន (បញ្ជូនអ្នកជំងឺមួយទៅមួយ) និងផ្តល់ឱសថសារវន្តដល់សមាជិកមិនគ្រប់គ្រាន់។

### ២.១.៣ បញ្ហាប្រឈមលើការជំរុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន

- កង្វះធនធានមនុស្ស

[71] បេឡាជាតិរបបសន្តិសុខសង្គម, (២០០៨-២០១៧),របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ, លេខទំព័រទី២៨

- ខ្វះជំនាញការសម្រាប់ការគណនាគណិតវិទ្យាលើការបង់ភាគទាន និងការផ្តល់តារកាលិក
- ខ្វះទិន្នន័យដែលជាមូលដ្ឋានសម្រាប់ការសិក្សា និងវិភាគ
- មិនទាន់រៀបចំសិក្សាសមិទ្ធិលទ្ធភាពនៃការអនុវត្ត។

**២.២. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

- ការចុះបញ្ជីមន្ត្រីសាធារណៈមិនទាន់ឆ្លើយតបទៅនិងមន្ត្រីរាជការសរុប
- មន្ត្រីសាធារណៈមិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ដែលខ្លួនត្រូវទទួលបាន
- ការផ្សព្វផ្សាយនៅមិនទាន់ទូលំទូលាយ។

**២.៣.ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន**

- ពិបាកក្នុងការអញ្ជើញនិយោជកមកចុះបញ្ជី សហគ្រាស និងកម្មករនិយោជិត
- និយោជកមិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ដែលកម្មករនិយោជិតនឹងទទួលបាន
- ការជូនដំណឹងមក ប.ស.សមានការយឺតយ៉ាវ
- កម្មករនិយោជិតជាស្ត្រីមិនមានអត្តសញ្ញាណប័ណ្ណ ឬអត្តសញ្ញាណប័ណ្ណមិនច្បាស់-លាស់
- កម្មករនិយោជិតមិនទាន់យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធធនាគារ
- ទូរស័ព្ទមិនមែនជាប្រភេទស្មាតហ្វូន

**២.៤.ការខាតគាំទ្រការអនុវត្ត**

- បញ្ហាធនធានមនុស្សនៅមានកម្រិត
- ការអនុវត្តរបបសន្តិសុខសង្គមមិនទាន់ទូលំទូលាយ
- ពិបាករកជំនាញវេជ្ជបណ្ឌិត
- បញ្ហាសន្លប់នៅតែបន្តកើនឡើង
- គ្រោះថ្នាក់ចរាចរណ៍បង្កឡើងដោយអ្នកបើកបើដឹកកម្មករមានការកើនឡើង
- និយោជក និងកម្មករនិយោជិតមួយចំនួនមិនទាន់ស្គាល់ ប.ស.ស។

## ផ្នែកទី៣៖ ការដោះស្រាយ និងទិសដៅអនុវត្តបន្ត

ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យមានប្រសិទ្ធភាពទាន់ពេលវេលា និងដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានា បេឡាជាតិរបបសន្តិសុខសង្គមមានទិសដៅសំខាន់ៗមួយចំនួន។[72]

### ៣.១. ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

#### ៣.១.១ ការពង្រឹង និងការពង្រីកការអនុវត្តហានិភ័យការងារ

**ក. និយោជកសហគ្រាស គ្រឹះស្ថាន ត្រូវសហការ៖**

- បន្តផ្សព្វផ្សាយពន្យល់ណែនាំពីយន្តការអនុវត្តជាធរមាន
- បន្តព្យាយាមសម្របសម្រួលណាត់ជួបនៅពេលរសៀល និងពន្យល់ឱ្យអស់លទ្ធភាពមុននឹងចាត់វិធានការ
- ចុះសម្របសម្រួល និងពន្យល់ផ្ទាល់ ដើម្បីកំណត់ពីស្ថានភាពសហគ្រាសដំណើរការ ឬមិនដំណើរការ
- ព្យាយាមទំនាក់ទំនងផ្ទាល់ ដើម្បីជួយបង្រៀនឱ្យចេះរៀបចំឯកសារបង់ភាគទាន និងឯកសារទាមទារតាវកាលិក
- ចុះទៅទារផ្ទាល់តាមរយៈការដាក់លិខិតកំហិត។

**ខ. កម្មករនិយោជិតត្រូវ៖**

- ចុះសម្របសម្រួល និងពន្យល់ផ្ទាល់ពីគោលការណ៍ជាធរមាន
- ជំរុញឱ្យចុះសំបុត្រអាពាហ៍ពិពាហ៍
- ណែនាំឱ្យទៅយកសេវាជាមួយមូលដ្ឋានសុខាភិបាល ដែលចុះព្រមព្រៀងជាមួយ ប.ស.ស វិញ។

**គ. សេវាមូលដ្ឋានសុខាភិបាល**

- សម្របសម្រួលជាមួយនឹងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ដោយផ្តល់សេវាបានកាន់តែល្អប្រសើរ និងប្រជុំដោះស្រាយបញ្ហាប្រឈមនានា
- បន្តចុះកិច្ចព្រមព្រៀង និងដាក់ភ្នាក់ងារ ប.ស.ស នៅតាមមូលដ្ឋានសុខាភិបាលនោះ។

[72] បេឡាជាតិរបបសន្តិសុខសង្គម (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល១០ឆ្នាំ លេខទំព័រទី៣០

### ៣.១.២ ការពង្រឹង និងការអនុវត្តផ្នែកថែទាំសុខភាព

**ក. និយោជកសហគ្រាស គ្រឹះស្ថាន ត្រូវសហការ**

- ចុះពន្យល់នីតិវិធីនៃការកំណត់អត្តសញ្ញាណ សមាជិក និងការផ្តល់សេវា
- ណែនាំប្រាប់ពីរបៀបរៀបចំរបាយការណ៍ចំនួនបុគ្គលិកឱ្យបានត្រឹមត្រូវ។

**ខ. កម្មករនិយោជិតត្រូវ៖**

- ចុះពន្យល់អំពីការកំណត់អត្តសញ្ញាណសមាជិកថ្មី(ផ្សព្វផ្សាយសេចក្តីជូនដំណឹង លេខ១២៧ ក.ប/ស.ជ.ណ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុង ប.ស.ស)
- ចុះពន្យល់ និងផ្សព្វផ្សាយពីតាវកាលិកថែទាំសុខភាព និងសម្របសម្រួលសមាជិក ឱ្យប្រើប្រាស់សេវាតាមរយៈភ្នាក់ងារ ប.ស.ស នៅតាមមន្ទីរពេទ្យ។

**គ. សេវាមូលដ្ឋានសុខាភិបាល**

- ប្រជុំពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយក្នុងការផ្តល់ឱសថ និងសេវាឱ្យរលូន
- សម្របសម្រួល និងស្នើរសុំគ្រូពេទ្យមិនឱ្យផ្សព្វផ្សាយលក់ផលិតផលដល់សមាជិក
- បន្តចុះកំណត់កម្រិតផ្តល់សេវា និងកិច្ចព្រមព្រៀងទូទាំង ២៥រាជធានី-ខេត្ត
- ចុះពន្យល់ពីវិធីសាស្ត្រទូទាត់ថ្លៃសេវា
- ចុះពន្យល់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណសមាជិកនៅតាមមូលដ្ឋានសុខាភិបាលតាមរយៈប្រព័ន្ធ SMS and H-SPIS ។

### ៣.១.៣. ការជំរុញការរៀបចំ និងដាក់ឱ្យដំណើរការផ្នែកសោធន

- ជ្រើសរើសបុគ្គលិក និងបណ្តុះបណ្តាលធនធានមនុស្ស
- ស្នើរសុំសហការជាមួយនឹងដៃគូអភិវឌ្ឍ ក្នុងការរៀបចំយន្តការអនុវត្ត និងបណ្តុះបណ្តាលធនធានមនុស្ស
- ស្នើរសុំពីដៃគូអភិវឌ្ឍឱ្យមានជំនាញការគណិតវិទ្យាក្នុងការស្រាវជ្រាវ និងប្រមូលទិន្នន័យសម្រាប់ ធ្វើការវិភាគលើការបង់ភាគទាន និងសេវាត្រូវផ្តល់
- រៀបចំសិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យអនុវត្ត ស្នើសុំគោលការណ៍ដាក់ឱ្យអនុវត្ត និងរៀបចំលិខិតបទដ្ឋានគតិយុត្ត។

## ៣.២. ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

- ជម្រុញការចុះបញ្ជីមន្ត្រីសាធារណៈដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពសាមី

- ត្រូវបង្កើនការផ្សព្វផ្សាយគ្រប់វិធីសាស្ត្រតាមរយៈ
    - ការប្រជុំផ្សព្វផ្សាយដោយផ្ទាល់
    - ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ហ្វេសបុក គេហទំព័រ និង
    - តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។

### ៣.៣.ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

- ជម្រុញការចុះអញ្ជើញនិយោជកឱ្យមកចុះបញ្ជីដើម្បីឱ្យកម្មករទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គម
- ជម្រុញឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- ជម្រុញការផ្សព្វផ្សាយព័ត៌មានដល់និយោជក ឬអ្នកតំណាង និងកម្មករនិយោជិត
- ព្យាយាមពន្យល់ដល់កម្មករនិយោជិតដោយផ្ទាល់ នៅពេលកម្មករនិយោជិតមកបំពេញទម្រង់ឯកសារ ស្នើរសុំប្រាក់ឧបត្ថម្ភនៅទីស្នាក់ការ ប.ស.ស
- ណែនាំឱ្យកម្មករនិយោជិតយល់ពីលេខទូរស័ព្ទបន្ទាន់ ១២៨៦
- ពន្យល់ និងជម្រុញឱ្យមានអត្តសញ្ញាណប័ណ្ណច្បាស់លាស់។

❖ **ការងារគាំទ្រការអនុវត្ត**

១.ករណីធនធានមនុស្សនៅមានកម្រិត

- រៀបចំវគ្គបណ្តុះបណ្តាល
- ស្នើសុំដៃគូអភិវឌ្ឍន៍វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សសម្រាប់រយៈពេលវែង

២.រៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

៣.រៀបចំលក្ខន្តិកៈដោយឡែកសម្រាប់លើកទឹកចិត្តបន្ថែមលើជំនាញវេជ្ជបណ្ឌិត

៤.បង្កើនការផ្សព្វផ្សាយពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ វិធានការទប់ស្កាត់ករណីសន្លប់

៥.ករណីគ្រោះថ្នាក់ចរាចរណ៍

➢ សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធជម្រុញឱ្យអ្នកបើកបរត្រូវះ

- ផ្លាស់ប្តូររថយន្តដឹកទំនិញ រថយន្តទ្រុងដែលកែច្នៃខុសច្បាប់ មកប្រើប្រាស់រថយន្តដឹកជញ្ជូនអ្នកដំណើរដែលមានកៅអីត្រឹមត្រូវ
- ចុះបង្រៀនអំពីច្បាប់ស្តីពីចរាចរណ៍ដល់អ្នកបើកបររថយន្តដឹកកម្មករ

៦.បង្កើនការផ្សព្វផ្សាយពីគោលនយោបាយរបបសន្តិសុខសង្គមដល់និយោជក និងកម្មករនិយោជិតឱ្យបានកាន់តែទូលំទូលាយ។

# សេចក្ដីសន្និដ្ឋាន

ក្នុងការអនុវត្តការងាររបស់ប.ស.ស រយៈពេល១០ឆ្នាំ នៃការអនុវត្តតាមច្បាប់ស្ដីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ និងអនុក្រឹត្យស្ដីពីការបង្កើត ប.ស.ស សម្រេចបានសមិទ្ធផលគួជាទីមោទនៈដោយផ្អែកលើ យុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្រអភិវឌ្ឍជាតិ យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុទ្ធសាស្ត្រគាំពារសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារឆ្នាំ២០១៤-២០១៨។

ទន្ទឹមនឹងលទ្ធផលការងារខាងលើ ប.ស.ស បានសង្កេតឃើញនៅមានបញ្ហាប្រឈមមួយចំនួនទៀត ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចមិនទាន់បានល្អប្រសើរពីសំណាក់និយោជក និងកម្មករនិយោជិតមួយចំនួនតូច គុណភាពនៃការផ្ដល់សេវាថែទាំវេជ្ជសាស្ត្រ ត្រូវបានកែលំអជាបន្តបន្ទាប់ និងបញ្ហារបស់ ប.ស.ស មួយចំនួន។ ទាក់ទងនឹងបញ្ហាប្រឈមនេះ ប.ស.ស ក៏បានកត់សម្គាល់ឃើញថាចំនួនគ្រោះថ្នាក់ការងារ គឺនៅតែមានការកើនឡើងស្របនឹងការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលបានចុះបញ្ជិកានៅ ប.ស.ស ជាពិសេសករណីរបួសធ្ងន់ ទោះបីជាករណីគ្រោះថ្នាក់ នៅពេលធ្វើដំណើរមានការកើនឡើងបន្តិចក៏ដោយ ក៏ករណីនេះនៅតែមានចំនួនគួរឱ្យព្រួយបារម្ភ។ ដូចនេះដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមខាងលើទាមទារឱ្យមានការបន្តជួយជ្រោមជ្រែង គាំទ្រសហការបន្ថែមទៀតពីសំណាក់ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានានៅក្នុងការអភិវឌ្ឍវិស័យសន្តិសុខសង្គម នៅកម្ពុជាឱ្យមានការរីកចំរើន និងសូមឱ្យមានការចូលរួមយ៉ាងសកម្ម ក្នុងការចាត់វិធានការអប់រំផ្សព្វផ្សាយ ដើម្បីបង្ការនិងទប់ស្កាត់ក្នុងកម្រិតគ្រោះថ្នាក់ការងារឱ្យនៅទាបបំផុត ដែលជាផ្នែកមួយចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថេរភាពសង្គម។ ម្យ៉ាងវិញទៀត កម្មករនិយោជិតខ្លួនឯងផ្ទាល់ត្រូវមានការយល់ដឹងបញ្ហាសុខភាព និងប្រុងប្រយ័ត្នខ្ពស់ក្នុងការបំពេញការងារ ជាពិសេសពេលធ្វើដំណើរទៅមក ដើម្បីជៀសវាងកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ព្រោះវានាំឱ្យមានការខាត់បង់ការងារ ពេលវេលា ថវិកា និងជាយថាហេតុបណ្ដាលឱ្យបាត់បង់ដល់អាយុជីវិតទៀត។

ផ្អែកលើសមិទ្ធផលសម្រេចកន្លងមកដោយសារថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស ទាំងអស់បានយកចិត្តទុកដាក់បំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងឆន្ទៈទទួលខុសត្រូវខ្ពស់ ថែទាំមានការគាំទ្រសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍនានា និងការចូលរួមអនុវត្តច្បាប់បានល្អប្រសើរពីសំណាក់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។

# អនុសាសន៍

ជាអនុសាសន៍ ដើម្បីឆ្លើយតបនឹងស្ថានភាពជាក់ស្តែង ទាក់ទងនឹងការផ្តល់សេវាសុខាភិបាលជូនកម្មករនិយោជិត ប.ស.ស គួរចាត់វិធានការឱ្យបានម៉ឺងម៉ាត់ និងមានសូចនាករច្បាស់លាស់ ដើម្បីពិនិត្យនិងតាមដានមើលសកម្មភាពព្យាបាល កម្មករនិយោជិតដោយមន្ទីរព្យាបាលដែលបានចុះសន្យាជាមួយប.ស.សពោលដើម្បីធានាឱ្យមានការអនុវត្តរបបសន្តិសុខសង្គមកាន់តែមានប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។ ម្យ៉ាងទៀតដោយសារការយល់ដឹងរបស់កម្មករនិយោជិតនៅមានកម្រិត ទាក់ទងនឹងការទាមទារតាវកាលិកឧត្តមជីវីដែលសិទ្ធិវន្តជា ប្តី ឬប្រពន្ធ ឬកូន របស់ជនរងគ្រោះពុំមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ ឬសំបុត្រកំណើតដែលច្បាប់បានកំណត់ ប.ស.ស គួរណាស់មានការបន្ធូរបន្ថយឱ្យប្រើប្រាស់លិខិតផ្សេងៗ ដូចជាប័ណ្ណគ្រួសារជាដើម ដើម្បីឱ្យសិទ្ធិវន្តនោះមានសិទ្ធិទទួលបានតាវកាលិកនេះ ហើយការផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃការចូលជាសមាជិកប.ស.សនេះ គួរធ្វើឱ្យកាន់តែទូលំទូលាយជាងមុន។

ជាអវសានកថានៃសារណានេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បេឡាជាតិរបបសន្តិសុខសង្គម និងក្លាយជាស្ថាប័នបង្អែកមួយកាន់តែសំខាន់សម្រាប់ប្រជាពលរដ្ឋខ្មែរ ក្នុងការប្រឆាំងតទល់នឹងភាពក្រីក្រ ស្របនឹងការអនុវត្តយុត្តិសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

# ឯកសារយោង

## ➢ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
2. ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២
3. ច្បាប់ស្តីពីការងារ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ មីនា ១៩៩៧
4. អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម លេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ២០០៧
5. ប្រកាសស្តីពី រចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គម លេខ ២៨៧ បក/ប្រ.ក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨
6. ប្រកាសស្តីពី បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
7. ប្រកាសស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ៤៤៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
8. ប្រកាសស្តីពីការកែសម្រួល ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារាកាលិកហានិភ័យការងារ លេខ២៣៣ ក.ប/ប្រក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១
9. ប្រកាសស្តីពីតារាកាលិកហានិភ័យការងារ លេខ១០៩ក.ប/ប្រ. ចុះថ្ងៃទី១៦ខែមិថុនា ឆ្នាំ២០០៨ ប្រការ១១

## ➢ សៀវភៅ

1. ហេង លីណា ស្តីពីនីតិការងារ និងនីតិនិរភ័យការងារ ឆ្នាំ២០១៦-២០១៧
2. ប៊ួយ ធីតា មុខវិជ្ជានីតិការងារ ឆ្នាំសិក្សា ២០១២-២០១៣ ទំព័រទី១
3. Brigitte Hess Fallon Anne Marie Simon Droit du trabail et de la Securite Sociale (បារាំង ១៩៩៨)

➢ **ឯកសារផ្សេងៗ**

1. បេឡាជាតិរបបសន្តិសុខសង្គម, (២០០៨-២០១៧) របាយការណ៍ស្តីពី សមិទ្ធផលរយៈពេល ១០ឆ្នាំ

➢ **គេហទំព័រ**

1. គេហទំព័ររបស់បេឡាជាតិរបបសន្តិសុខសង្គម http://www.nssf.gov.kh/default/
2. http://www.ilo.org/global/lang--en/index.htm

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១**
    - អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសង្គម លេខ១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមិនា ឆ្នាំ២០០៧
- **ឧបសម្ព័ន្ធទី២**
    - ប្រកាសស្តីពី រចនាសម្ព័ន្ធគ្រប់គ្រងនៃបេឡាជាតិរបបសន្តិសុខសង្គម លេខ ២៨៧ បក/ប្រ.ក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨
    - ប្រកាសស្តីពី បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, លេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
    - ប្រកាសស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ លេខ៤៤៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
    - ប្រកាសស្តីពីការកែសម្រួល ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ លេខ២៣៣ ក.ប/ប្រក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១
    - ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ លេខ១០៩ក.ប/ប្រ. ចុះថ្ងៃទី១៦ខែមិថុនា ឆ្នាំ២០០៨ ប្រការ១១